អង្គការសហប្រជាជាតិ

A/HRC/57/78

មហាសន្និបាត

ការចែកចាយ៖ ទូទៅ
ថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២៤

ច្បាប់ដើម៖ ភាសាអង់គ្លេស

**ក្រុមប្រឹក្សាសិទ្ធិមនុស្ស**

**សម័យប្រជុំលើកទីហាសិបប្រាំពីរ**

ថ្ងៃទី០៩ ខែកញ្ញា - ថ្ងៃទី០៩ ខែតុលា ឆ្នាំ២០២៤

របៀបវារៈទី២ ដល់ ទី១០

**របាយការណ៍ប្រចាំឆ្នាំរបស់ឧត្តមស្នងការអង្គការ សហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស និង របាយការណ៍របស់ការិយាល័យឧត្តមស្នងការ និងអគ្គលេខាធិការ**

**ជំនួយបច្ចេកទេស និងការកសាងសមត្ថភាព**

# តួនាទី និងសមិទ្ធិផលរបស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស ក្នុងការផ្ដល់ជំនួយដល់រដ្ឋាភិបាល និងប្រជាជនកម្ពុជា ក្នុងការលើកកម្ពស់ និងការការពារសិទ្ធិមនុស្ស

## របាយការណ៍របស់អគ្គលេខាធិការ*

*សេចក្ដីសង្ខេប*

ដោយបានដាក់ជូន យោងតាមសេចក្ដីសម្រេចលេខ ៥៤/៣៦ របស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស របាយការណ៍បច្ចុប្បន្នគូសបញ្ជាក់អំពីតួនាទី និងសមិទ្ធិផលរបស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) នៅកម្ពុជា ចាប់ពីថ្ងៃទី០១ ខែមិថុនា ឆ្នាំ ២០២៣ ដល់ ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២៤។

*មានការព្រមព្រៀងគ្នាលើការបោះពុម្ពផ្សាយឯកសារបច្ចុប្បន្ន នៅក្រោយកាលបរិច្ឆេទស្ដង់ដារដែលបានកំណត់សម្រាប់បោះពុម្ពផ្សាយ ដោយសារស្ថានភាពដែលហួសពីលទ្ធភាពដែលអ្នកដាក់ជូនឯកសារអាចគ្រប់គ្រងបាន។

ក្នុងអំឡុងពេលធ្វើរបាយការណ៍នេះ OHCHR បានបន្តកិច្ចសហប្រតិបត្តិការជាមួយក្រសួងផ្សេងៗនៃរដ្ឋាភិបាល គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា គណៈកម្មាធិការជាតិប្រឆាំងទារុណកម្ម ក្រុមប្រឹក្សាសកម្មភាពជនពិការ ក្រុមប្រឹក្សាជាតិគាំពារសង្គម និងតួអង្គដទៃទៀតនៃរដ្ឋាភិបាល ដើម្បីផ្តល់ជំនួយ និងដំបូន្មានផ្នែកបច្ចេកទេស ស្របតាមអនុស្សរណៈនៃការយោគយល់គ្នារវាងរដ្ឋាភិបាល និង OHCHR។ OHCHR ក៏បានចូលរួមក្នុងសកម្មភាពកសាងសមត្ថភាពរបស់តួអង្គសង្គមស៊ីវិល រួមទាំងពង្រឹងតួនាទីរបស់ពួកគេក្នុងការលើកកម្ពស់ និងការការពារសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ និងចូលរួមអនុវត្តយន្តការសិទ្ធិមនុស្សអន្តរជាតិ និងគាំទ្រដល់ការអនុវត្តអនុសាសន៍នៃយន្តការទាំងនោះផងដែរ។ របាយការណ៍នេះក៏បានគូសបញ្ជាក់អំពីការរឹតត្បិតចំពោះសិទ្ធិផ្សេងៗ ដូចជា សិទ្ធិចូលរួមក្នុងកិច្ចការសាធារណៈ និងសិទ្ធិសេរីភាពក្នុងបញ្ចេញមតិ រួមទាំងបរិបទនៃការបោះឆ្នោតថ្នាក់ជាតិ ឆ្នាំ២០២៣ ផងដែរ។

# I. សេចក្តីផ្តើម

1. របាយការណ៍បច្ចុប្បន្ន ដែលបានដាក់ជូន យោងតាមសេចក្តីសម្រេចលេខ ៥៤/៣៦ របស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស គូសបញ្ជាក់អំពីសកម្មភាព និងសមិទ្ធផលរបស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) ក្នុងការផ្តល់ជំនួយដល់រដ្ឋាភិបាល និងប្រជាជនកម្ពុជា ក្នុងការលើកកម្ពស់ និងការការពារសិទ្ធិមនុស្ស ចាប់ពីថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០២៣ រហូតដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២៤។

2. OHCHR បានផ្តល់ការគាំទ្រផ្នែកបច្ចេកទេសដល់អង្គចៅក្រម ក្រសួងយុត្តិធម៌ ក្រសួងមហាផ្ទៃ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងកិច្ចការនារី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា គណៈកម្មាធិការជាតិប្រឆាំងទារុណកម្ម ក្រុមប្រឹក្សាសកម្មភាពជនពិការ បេឡាជាតិរបបសន្តិសុខសង្គម និងក្រុមប្រឹក្សាជាតិគាំពារសង្គម និងភាគីពាក់ព័ន្ធដទៃទៀត នៅក្នុងជួររដ្ឋាភិបាល។ OHCHR បានបន្តពិនិត្យតាមដានស្ថានភាពសិទ្ធិមនុស្ស ដោយផ្តោតលើសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ សិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ រដ្ឋបាលយុត្តិធម៌ និងលក្ខខណ្ឌក្នុងការឃុំខ្លួន។ OHCHR ក៏បានផ្តល់ការគាំទ្រដល់ក្រុមការងារប្រចាំប្រទេសរបស់អង្គការសហប្រជាជាតិក្នុងការបញ្ជ្រាបសិទ្ធិមនុស្សទៅក្នុងក្របខណ្ឌកម្មវិធីថ្នាក់ជាតិ និងក្របខណ្ឌកិច្ចសហប្រតិបត្តិការលើការអភិវឌ្ឍន៍ប្រកបដោយចីរភាពរបស់អង្គការសហប្រជាជាតិសម្រាប់ប្រទេសកម្ពុជា នៅឆ្នាំ២០២៤-២០២៨ ព្រមទាំងតាមរយៈគំនិតផ្តួចផ្តើមសិទ្ធិមនុស្ស ៧៥ របស់ OHCHR ដើម្បីគម្រប់ខួបចិតសិបប្រាំឆ្នាំនៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្សផងដែរ។

3. OHCHR បានបន្តជួយរដ្ឋាភិបាលក្នុងការបង្កើតវឌ្ឍនភាពឆ្ពោះទៅរកការអនុវត្តកាតព្វកិច្ចសិទ្ធិមនុស្សអន្តរជាតិរបស់ខ្លួន និងអនុសាសន៍នៃយន្តការសិទ្ធិមនុស្សអន្តរជាតិ។ OHCHR បានផ្សព្វផ្សាយការអង្កេតសន្និដ្ឋានរបស់ស្ថាប័នសន្ធិសញ្ញា និងបានគាំទ្រដំណើរការពិគ្រោះយោបល់ថ្នាក់ជាតិសម្រាប់វដ្តនៃការត្រួតពិនិត្យតាមកាលកំណត់ជាសកលលើកទីបួន។ OHCHR បានផ្តល់ដំបូន្មានផ្នែកបច្ចេកទេសលើគំនិតផ្តួចផ្តើមផ្នែកនីតិបញ្ញត្តិ រួមទាំងសេចក្តីព្រាងច្បាប់ស្តីពីការការពារសិទ្ធិជនពិការ សេចក្តីព្រាង

វិសោធនកម្មច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល និងព្រះរាជក្រឹត្យស្តីពីអាជ្ញាធរជាតិដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ផងដែរ។

4. កាលពីខែធ្នូ ឆ្នាំ២០២៣ អ្នករាយការណ៍ពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា បានធ្វើទស្សនកិច្ចជាផ្លូវការនៅប្រទេសនេះ ដើម្បីពិគ្រោះយោបល់ជាមួយរដ្ឋាភិបាលថ្មីអំពីស្ថានភាពសិទ្ធិមនុស្ស និងទិសដៅនាពេលអនាគត។[1]

## II. បរិបទ

5. គណបក្សនយោបាយចំនួនដប់ប្រាំបី បានចូលរួមប្រកួតប្រជែងនៅក្នុងការបោះឆ្នោតថ្នាក់ជាតិលើកទីប្រាំពីរ ដែលបានប្រព្រឹត្តិទៅនៅថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២៣ ដោយមានអ្នកចូលរួមបោះឆ្នោតរហូតដល់ ៨៤,៥៩ ភាគរយ។ គណបក្សប្រជាជនកម្ពុជា ដែលកំពុងកាន់អំណាច បានទទួលអាសនៈរដ្ឋសភា ចំនួន ១២០ ក្នុងចំណោម ១២៥ អាសនៈ នៅខណៈពេលដែល គណបក្សរណសិរ្សបង្រួបបង្រួមជាតិដើម្បីកម្ពុជាឯករាជ្យ អព្យាក្រិត សន្តិភាព និងសហប្រតិបត្តិការ ទទួលបាន ៥ អាសនៈដែលនៅសល់។ ស្ត្រីចំនួនដប់ប្រាំពីររូប ត្រូវបានបោះឆ្នោតជ្រើសតាំងជាតំណាងរាស្ត្រនីតិកាលទីប្រាំពីរ មានចំនួនតិចជាងស្ត្រីដែលត្រូវបានបោះឆ្នោតជ្រើសតាំងជាតំណាងរាស្ត្រនីតិកាលទីប្រាំមួយ ចំនួន ៩ រូប ដែលនៅពេលនោះ មានចំនួន ២៦ រូប។ ស្ត្រីមួយរូបត្រូវបានបោះឆ្នោតជ្រើសតាំងជាប្រធានរដ្ឋសភានីតិកាលទីប្រាំពីរ ជាលើកដំបូង។ នៅថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ សភាបានអនុម័តលោក ហ៊ុន ម៉ាណែត ជានាយករដ្ឋមន្ត្រីថ្មីរបស់ប្រទេសនេះ បន្ទាប់ពីមានការឯកភាពនៅក្នុងកិច្ចប្រជុំគណៈកម្មាធិការមជ្ឈិមបក្សលើកទីសែសិបបី។

6. វដ្តនៃការបោះឆ្នោតលើកនេះបានមើលឃើញកង្វះខាតការចូលរួមផ្នែកនយោបាយបន្ថែមទៀតពីក្រុមប្រឆាំង បន្ទាប់ពីមានការរំលាយគណបក្សប្រឆាំងធំបំផុតរបស់ប្រទេស នៅឆ្នាំ២០១៧ ព្រមទាំងការរឹតត្បិតសិទ្ធិមនុស្ស និងការបំភិតបំភ័យសង្គមស៊ីវិល និងតួអង្គនយោបាយ។ នៅថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០២៣ ឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សបានសម្តែងការសោកស្តាយ ដែលការបោះឆ្នោតថ្នាក់ជាតិបានប្រព្រឹត្តទៅនៅកន្លែងដែលមានការរឹតត្បិតយ៉ាងធ្ងន់ធ្ងរ ដែលមានផលជះអវិជ្ជមានដល់សិទ្ធិរបស់ប្រជាជនកម្ពុជា ក្នុងការចូលរួមយ៉ាងពេញលេញ និងប្រកបដោយសមភាព នៅក្នុងដំណើរការបោះឆ្នោត។[2]

7. នៅថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០២៤ គណបក្សនយោបាយចំនួនបួនបានចូលរួមប្រកួតប្រជែងក្នុងការបោះឆ្នោតព្រឹទ្ធសភានីតិកាលទីប្រាំ ដោយគណបក្សប្រជាជនកម្ពុជាទទួលបាន ៥៥ អាសនៈ ក្នុងចំណោម ៥៨ អាសនៈដែលឈ្នះការបោះឆ្នោត និងគណបក្សឆន្ទៈខ្មែរទទួលបានអាសនៈចំនួនបីដែលនៅសល់។ ស្ត្រីចំនួនដប់មួយរូបត្រូវបានបោះឆ្នោតជ្រើសតាំង ឬតែងតាំងជាសមាជិកព្រឹទ្ធសភាដែលមានសមាសភាពដូចគ្នានឹងសមាជិកព្រឹទ្ធសភាកាលពីមុនដែរ។ នៅខែមេសា ឆ្នាំ២០២៤ លោក

1 សូមមើល https://www.ohchr.org/en/press-releases/2023/12/un-expert-cambodia-conduct-official-country-visit.

2 សូមមើល https://www.ohchr.org/en/press-releases/2023/07/cambodia-un-human-rights-chief-regrets-elections-held-restrictive.

ហ៊ុន សែន អតីតនាយករដ្ឋមន្ត្រី បានធ្វើការស្បថចូលកាន់តំណែងជាប្រធានព្រឹទ្ធសភា។

# III. សិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

## ក. ម៉ាក្រូសេដ្ឋកិច្ច ភាពក្រីក្រ និងការបែងចែកថវិកា

8. ផលិតផលក្នុងស្រុកសរុប (GDP) របស់ប្រទេសកម្ពុជាបានកើនឡើង ៥,0 ភាគរយនៅឆ្នាំ ២០២៣ និងត្រូវបានព្យាករណ៍ថានឹងកើនឡើង ៦,0 ភាគរយនៅឆ្នាំ២០២៤។[3] ទោះបីជាមានផលជះនៃជម្លោះក្រៅប្រទេស និងបញ្ហាភូមិសាស្ត្រនយោបាយក៏ដោយ ក៏អត្រាអតិផរណាប្រចាំឆ្នាំជាមធ្យមនៅកម្ពុជា បានថយចុះមកត្រឹម ២,១ ភាគរយនៅឆ្នាំ២០២៣ ធៀបនឹង ៥,៤ ភាគរយនៅឆ្នាំ២០២២។[4] កំណើន GDP ប្រសិនបើអមដោយការកើនឡើងនៃប្រាក់ចំណូលរបស់រដ្ឋាភិបាល និងការថយចុះនៃអតិផរណានោះ អាចទ្រទ្រង់កំណើនចំណាយសាធារណៈ និងការបង្កើនលទ្ធភាពទទួលបានសេវាសំខាន់ៗ ដែលនឹងជំរុញឲ្យមានបរិយាកាសកាន់តែអំណោយផលដល់ការទទួលបានសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌។

9. ភាពក្រីក្រមានការថយចុះនៅប្រទេសកម្ពុជា ដោយអត្រាភាពក្រីក្រពហុវិមាត្របានធ្លាក់ចុះជាង ៥0 ភាគរយ ពី ៣៦,៧ ភាគរយនៅឆ្នាំ២០១៤ មកត្រឹម ១៦,៦ ភាគរយនៅឆ្នាំ២០២១/២២។ ក្នុងអំឡុងរយៈពេលដូចគ្នានេះ អត្រាភាពក្រីក្ររបស់កុមារបានធ្លាក់ចុះពី ៤២,៧ ភាគរយ មកត្រឹម ២០,៥ ភាគរយ។[5] សន្ទស្សន៍អភិវឌ្ឍន៍មនុស្សបានកើនឡើងពី 0,៥៩៦ ក្នុងឆ្នាំ២០២១ ដល់ 0,៦00 ក្នុងឆ្នាំ២០២២ ដោយប្រទេសកម្ពុជាបានជាប់ចំណាត់ថ្នាក់ ១៤៨ ក្នុងចំណោម ១៨៥ ប្រទេស។[6] ការកាត់បន្ថយភាពក្រីក្រ ការកែលម្អសន្ទស្សន៍អភិវឌ្ឍន៍មនុស្ស និងអនុសាសន៍សម្រាប់ប្រទេសកម្ពុជាក្នុងការចាកចេញពីស្ថានភាពជាប្រទេសអភិវឌ្ឍន៍តិចតួចនៅឆ្នាំ២០២៩[7] បង្ហាញថា ជីវភាពរស់នៅ និងលទ្ធភាពទទួលបានសេវាសំខាន់ៗ ជារួម មានភាពប្រសើរឡើង។ ទោះបីជាយ៉ាងណាក៏ដោយ នៅតែមានកង្វល់ទាក់ទងនឹងគុណភាពនៃសេវាទាំងនេះ និងលទ្ធភាពទទួលបានសេវាទាំងនេះប្រកបដោយបរិយាប័ន្ន។

10. យោងតាមរដ្ឋាភិបាល បំណុលសាធារណៈបានកើនឡើងពី ២៤,៤ ភាគរយនៃ GDP ក្នុងឆ្នាំ ២០២២ ដល់ ២៤,៦ ភាគរយនៅឆ្នាំ២០២៣ ក្នុងនោះ បំណុលខាងក្រៅមានចំនួន ៩៩,៥ ភាគរយ

[3] International Monetary Fund (IMF), World Economic Outlook: Steady but Slow – Resilience amid Divergence (2024), p. 142.

[4] ធនាគារជាតិនៃកម្ពុជា របាយការណ៍ប្រចាំឆ្នាំ២០២៣ ទំ.១១ រកមើលបាននៅក្នុងគេហទំព័រ៖ https://www.nbc.gov.kh/download_files/publication/annual_rep_eng/NBC Annual Report 2023Eng.pdf.

[5] United Nations Development Programme (UNDP) and Oxford Poverty and Human Development Initiative, "Global Multidimensional Poverty Index 2023: unstacking global poverty – data for high impact action" (2023), p. 15.

[6] UNDP, Human Development Report 2023/2024: Breaking the Gridlock – Reimagining Cooperation in a Polarized World (New York, 2024), pp. 276 and 281.

[7] United Nations LDC Portal, "Cambodia graduation status", available at https://www.un.org/ldcportal/content/cambodia-graduation-status.

ប្រហែល ១១,២៣៧ លានដុល្លារនៃបំណុលសាធារណៈ ក្នុងឆ្នាំ២០២៣។[8] ស្រដៀងគ្នានឹងឆ្នាំ២០២២ ដែរ នៅឆ្នាំ២០២៣ ប្រទេសកម្ពុជាបានលៃលកប្រាក់ ៧,១ ភាគរយនៃប្រាក់ចំណូលរបស់ខ្លួន សម្រាប់សេវាបំណុល។ ទោះបីជាមានការប្រមើលមើលថា នឹងមានកំណើនបំណុលសាធារណៈបន្តិចបន្តួចធៀបនឹង GDP ក្នុងរយៈពេលមធ្យមក៏ដោយ ក៏ហានិភ័យនៃវិបត្តិបំណុលនៅតែមានកម្រិតទាបដែរ។[9] ទោះបីជាយ៉ាងណាក៏ដោយ ចំណាយថ្នាក់ជាតិ ដែលរួមបញ្ចូលទាំងចំណាយថ្នាក់ក្រោមជាតិផងដែរនោះ ត្រូវបានប៉ាន់ស្មានថាមានការថយចុះប្រហែល ៥,០ ភាគរយ ដោយបានធ្លាក់ចុះពី ៤០,០៤ ទ្រីលានរៀល (ប្រហែល ៩,៧៤៥ ពាន់លានដុល្លារ) ក្នុងឆ្នាំ២០២៣ មកត្រឹម ៣៨,០៦ ទ្រីលានរៀលកម្ពុជា (ប្រហែល ៩,២៦៣ ពាន់លានដុល្លារ) ក្នុងឆ្នាំ២០២៤។[10] ការថយចុះនេះបានជះឥទ្ធិពលដល់វិស័យសុខាភិបាល ដែលការបែងចែកថវិកាបានថយចុះពី ២,៩ ទ្រីលានរៀល (ប្រហែល ៧០៥ លានដុល្លារ) ក្នុងឆ្នាំ២០២៣ មកត្រឹម ២,៧ ទ្រីពាន់លានរៀល (ប្រមាណ ៦៥៧ លានដុល្លារ) ក្នុងឆ្នាំ២០២៤។ បញ្ហាប្រឈមដទៃទៀត ទាក់ទងនឹងកង្វះការចូលរួមរបស់ភាគីពាក់ព័ន្ធ រួមទាំងស្ត្រីផងដែរ នៅក្នុងដំណើរការថវិកា និងភាពអាចស្វែងរកបាននៃព័ត៌មានដែលមានការបែងចែក ស្តីពីការបែងចែកថវិកាទៅកាន់វិស័យខុសៗគ្នា ដូចជា វិស័យអប់រំ ជាដើម។

11. នៅខែសីហា ឆ្នាំ២០២៣ រដ្ឋាភិបាលបានដាក់ចេញនូវយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ ឆ្នាំ២០២៣-២០២៨ ដើម្បីជំរុញភាពរីកចម្រើន បង្កើតការងារ ធានាបាននូវសមធម៌ បង្កើនប្រសិទ្ធភាព និងរក្សានិរន្តរភាព ក្នុងគោលបំណងក្លាយជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់ក្នុងឆ្នាំ២០៣០ និងប្រទេសដែលមានចំណូលខ្ពស់ ក្នុងឆ្នាំ២០៥០។[11]

12. នៅក្នុងបរិបទនេះ OHCHR បានបន្តផ្តល់ការគាំទ្រផ្នែកបច្ចេកទេសដល់រដ្ឋាភិបាល និងតួអង្គសង្គមស៊ីវិល ដើម្បីលើកកម្ពស់ការសម្រេចបាននូវវឌ្ឍនភាពនៃសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌។ ក្នុងខែតុលា ឆ្នាំ២០២៣ OHCHR បានគាំទ្រគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា ក្នុងការរៀបចំសិក្ខាសាលាស្តីពីការអង្កេតសន្និដ្ឋានរបស់គណៈកម្មាធិការសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដើម្បីលើកកម្ពស់សិទ្ធិទាំងនេះ។[12] សិក្ខាសាលានេះបានប្រមូលផ្តុំអ្នកចូលរួមចំនួន ១០៥ នាក់ (ស្ត្រី ៣២ នាក់ និងបុរស ៧៣ នាក់) មកពីក្រសួងរដ្ឋាភិបាល និងភាគីពាក់ព័ន្ធដទៃទៀត ដើម្បីចែករំលែកផែនការជាតិដើម្បីអនុវត្តអនុសាសន៍របស់គណៈកម្មាធិការ ព្រមទាំងពិភាក្សាអំពីយុទ្ធសាស្ត្រ និងតួនាទីក្នុងការពិនិត្យតាមដានការអនុវត្តផងដែរ។ OHCHR ក៏បានគាំទ្រការបកប្រែជាភាសាខ្មែរ និងការផ្សព្វផ្សាយគោលការណ៍ណែនាំរបស់អង្គការសហប្រជាជាតិស្តីពីភាពក្រីក្រខ្លាំង និងសិទ្ធិមនុស្ស ក្នុងខែកញ្ញា ឆ្នាំ

[8] ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុកម្ពុជា "ព្រឹត្តិបត្រស្ថិតិបំណុលសាធារណៈកម្ពុជា" ច្បាប់ទី ២១ (ខែកុម្ភៈ ឆ្នាំ២០២៤) ទំ. ៥ និង ៦ មាននៅ https://gdicdm.mef.gov.kh/en/2024/02/16/11166.html.

[9] IMF "បុគ្គលិក IMF បញ្ចប់បេសកកម្មនៃមាត្រា IV ឆ្នាំ២០២៣ នៅប្រទេសកម្ពុជា" ថ្ងៃទី៣១ ខែតុលា ឆ្នាំ២០២៣ មាននៅ https://www.imf.org/en/News/Articles/2023/10/30/pr23365-cambodia-imf-staff-completes-2023-article-iv-mission.

[10] រាជរដ្ឋាភិបាលកម្ពុជា ច្បាប់គ្រប់គ្រងហិរញ្ញវត្ថុ ឆ្នាំ២០២៤ មាននៅ https://mef.gov.kh/download-counter?post=9933 (ជាភាសាខ្មែរ).

[11] រាជរដ្ឋាភិបាលកម្ពុជា យុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ ខែសីហា ឆ្នាំ២០២៣ ទំ. ២៣ និង ២៤ មាននៅ https://www.mfaic.gov.kh/files/uploads/1XK1LW4MCTK9/EN PENTAGONALSTRATEGY - PHASE I.pdf. ទំ. ២៣ និង ២៤.

[12] E/C.12/KHM/CO/2.

២០២៣ ផងដែរ។[13]

13. នៅថ្ងៃទី០៦ ខែតុលា ឆ្នាំ២០២៣ OHCHR បានជួបប្រជុំជាមួយតំណាងអង្គការមិនមែនរដ្ឋាភិបាល (NGOs) ដើម្បីរៀបចំយុទ្ធសាស្ត្រសម្រាប់ការចូលរួមរបស់ពួកគេជាមួយក្រសួងរដ្ឋាភិបាល ក្នុងការអនុវត្តអនុសាសន៍របស់គណៈកម្មាធិការសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌។ នៅថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២៤ OHCHR បានរៀបចំការពិគ្រោះយោបល់សម្រាប់អ្នកតំណាងចំនួន ១៩ នាក់ (ស្ត្រី ៥ នាក់ និង បុរស ១៤ នាក់) មកពី ១៣ NGOs ដើម្បីកសាងសមត្ថភាពរបស់ពួកគេលើសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ និងពិនិត្យតាមដានការអនុវត្តអនុសាសន៍ដែលពាក់ព័ន្ធ ដែលទទួលបានពីយន្តការសិទ្ធិមនុស្សអន្តរជាតិ។

## ខ. សិទ្ធិសន្តិសុខសង្គម

14. OHCHR បានបន្តពិនិត្យតាមដានការអភិវឌ្ឍ ពាក់ព័ន្ធនឹងប្រព័ន្ធគាំពារសង្គមនៅប្រទេសកម្ពុជា។ ជាផ្នែកមួយនៃគំនិតផ្តួចផ្តើមសិទ្ធិមនុស្ស ៧៥ របស់ OHCHR រដ្ឋាភិបាលបានសន្យាបន្តអភិវឌ្ឍ និងពង្រីកប្រព័ន្ធគាំពារសង្គម ត្រឹមខែកក្កដា ឆ្នាំ២០២៨ ក្នុងគោលបំណងមិនទុកនរណាម្នាក់ចោល[14] ដែលត្រូវបានកំណត់អាទិភាព នៅក្រោមយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១[15]។

15. រដ្ឋាភិបាលបានប្រកាសថា រដ្ឋាភិបាលនឹងដាក់ចេញនូវក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម – ចក្ខុវិស័យឆ្នាំ២០៣០ ជំនួសឲ្យក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ឆ្នាំ២០១៦-២០២៥។ បើទោះបីជាក្របខណ្ឌថ្មីនេះប្រើអភិក្រមវដ្តជីវិតសម្រាប់កិច្ចគាំពារសង្គមនោះ ប៉ុន្តែវាមិនស្របទៅនឹងគោលការណ៍ជាច្រើននៃអនុសញ្ញាស្តីពីសន្តិសុខសង្គម (បទដ្ឋានអប្បបរមា) ឆ្នាំ១៩៥២ (លេខ ១០២) ដូចជា គោលការណ៍ស្តីពីការធានាចំពោះអត្ថប្រយោជន៍ដែលត្រូវបានកំណត់ និងការចូលរួមរបស់កម្មករ និងនិយោជិតឡើយ។[16] OHCHR ដោយមានការសម្របសម្រួលជាមួយក្រុមការងារប្រចាំប្រទេសរបស់អង្គការសហប្រជាជាតិ បានបន្តផ្តល់ការគាំទ្រដល់រដ្ឋាភិបាល ដើម្បីធានាថា គោលនយោបាយទាំងនោះបានគិតគូរអំពីបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិដែលពាក់ព័ន្ធ ដូចជា ការចូលរួមរបស់អ្នកទទួលផល តម្លាភាព គណនេយ្យភាព និងការមិនរើសអើង ជាដើម។

16. នៅខែធ្នូ ឆ្នាំ២០២៣ រដ្ឋាភិបាលបានដាក់ចេញនូវគោលការណ៍ណែនាំស្តីពីក្របខណ្ឌកិច្ចគាំពារសង្គមឆ្លើយតបនឹងគ្រោះអាសន្ន និងគោលការណ៍ណែនាំស្តីពីក្របខណ្ឌកម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់គ្រួសារ ដែលបានធ្វើសមាហរណកម្ម និងជំនួសឲ្យកម្មវិធីជំនួយសង្គមជាច្រើន សម្រាប់ក្រុមដែលស្ថិតក្នុងស្ថានភាពងាយរងគ្រោះ ដូចជា កម្មវិធីផ្ទេរសាច់ប្រាក់នៅពេលមានជំងឺរាតត្បាតកូវីដ-១៩ ជាដើម ដែលមានអត្ថិភាពមុនពេលមានគោលការណ៍ណែនាំទាំងនេះ។ គោលការណ៍ណែនាំស្តីពីក្របខណ្ឌកិច្ចគាំពារសង្គមឆ្លើយតបនឹងគ្រោះអាសន្ន មានបំណងផ្តល់ការគាំទ្រក្រោមការសម្របសម្រួល

[13] សូមមើល https://www.ohchr.org/en/special-procedures/sr-poverty/guiding-principles-extreme-poverty-and-human-rights.

[14] OHCHR "ពាក្យសន្យាផ្នែកសិទ្ធិមនុស្ស លើកទី ៧៥៖ ប្រទេសកម្ពុជា" ខែធ្នូ ឆ្នាំ២០២៣ មាននៅ https://www.ohchr.org/sites/default/files/udhr/publishingimages/75udhr/Cambodia_EN.pdf.

[15] សូមមើល ទំ. ២៣ និង ២៤.

[16] សូមមើល ឧទាហរណ៍ មាត្រា ៧២.

និងជាប្រព័ន្ធដល់បុគ្គល និងសហគមន៍ដែលរងផលប៉ះពាល់ដោយគ្រោះអាសន្ន ដូចជា គ្រោះធម្មជាតិ ឬវិបត្តិសេដ្ឋកិច្ច ជាដើម។

17. នៅខែមេសា ឆ្នាំ២០២៤ រដ្ឋាភិបាលបានផ្តួចផ្តើមយុទ្ធនាការចុះបញ្ជីសម្រាប់កម្មវិធីកញ្ចប់គ្រួសារ ដែលផ្តល់ជំនួយជាសាច់ប្រាក់ប្រចាំខែដល់គ្រួសារដែលស្ថិតក្នុងស្ថានភាពងាយរងគ្រោះ។ យោងតាមមូលនិធិជាតិជំនួយសង្គម គិតត្រឹមថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២៤ ប្រជាជន ៥១០.៦០០ គ្រួសារ ក្នុងចំណោម ៦៤៥.២៧១ គ្រួសារ នៅក្នុងកម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្ររបស់រដ្ឋាភិបាល (ឬ ៧៩ ភាគរយ) បានចុះបញ្ជីរួចរាល់ហើយ។ ទោះបីជាយ៉ាងណាក៏ដោយ កញ្ចប់គ្រួសារផ្តល់ប្រាក់ឧបត្ថម្ភកម្រិតមូលដ្ឋានជាអប្បបរមា (មិនរួមបញ្ចូលអត្ថប្រយោជន៍សម្រាប់សមាជិកគ្រួសារក្នុងស្ថានភាពងាយរងគ្រោះ ដូចជា ស្ត្រីមានផ្ទៃពោះ មនុស្សចាស់ និងជនពិការ ជាដើម) ចំនួន ៨,៥០ ដុល្លារក្នុងមួយខែ ដែលទាបជាងទឹកប្រាក់ប្រហែល ២០ និង ៣០ ដុល្លារក្នុងមួយខែ ដែលបានផ្តល់ជូនគ្រួសារនៅតាមជនបទ និងទីក្រុងរៀងៗគ្នា នៅក្រោមកម្មវិធីផ្ទេរសាច់ប្រាក់នៅពេលមានជំងឺរាតត្បាតកូវីដ-១៩ ដែលបានកែសម្រួលកាលពីមុន នៅខែធ្នូ ឆ្នាំ២០២៣។[17]

18. នៅខែសីហា ឆ្នាំ២០២៣ រដ្ឋាភិបាលបានប្រកាសអំពីរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពតាមរបបភាគទានដោយស្ម័គ្រចិត្តថ្មីមួយ សម្រាប់បុគ្គលស្វ័យនិយោជន៍ និងស្វាមី ភរិយា និងកូនៗរបស់ពួកគេ ដែលការអនុវត្តរបបនេះបានចាប់ផ្តើមក្នុងខែវិច្ឆិកា ឆ្នាំ២០២៣[18] ដោយពង្រីកការគ្របដណ្តប់លើមនុស្សមួយចំនួនធំ រួមទាំងស្វាមី ភរិយា និងកូនៗរបស់ពួកគេផងដែរ ដែលកាលពីមុន មិនត្រូវបានរួមបញ្ចូលនោះទេ។

19. ការិយាល័យ OHCHR បាន និងកំពុងធ្វើការវាយតម្លៃភាពអាចស្វែងរកបាន និងលទ្ធភាពទទួលបានរបបគាំពារសង្គមសម្រាប់អ្នកធ្វើការនៅក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ។ ការវាយតម្លៃនេះមានបំណងជួយរដ្ឋាភិបាល កំណត់វិធីធ្វើសមាហរណកម្មអ្នកធ្វើការទាំងនោះទៅក្នុងរបបគាំពារសង្គម និងធានាបាននូវភាពអាចផ្គត់ផ្គង់បាន តាមរយៈការកំណត់ភាគទានដែលចាំបាច់ជាមុន ស្របតាមកាតព្វកិច្ចសិទ្ធិមនុស្សអន្តរជាតិរបស់ខ្លួន។[19]

20. OHCHR បានពិភាក្សាជាមួយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា អំពីការវាយតម្លៃឆន្ទៈរបស់អ្នកធ្វើការក្នុងវិស័យក្រៅប្រព័ន្ធ ក្នុងការផ្តល់ភាគទានដល់របបធានារ៉ាប់រងសុខភាព

[17] ប្រៀបធៀប រាជរដ្ឋាភិបាលកម្ពុជា អនុក្រឹត្យលេខ ៣៧២ ស្តីពីការអនុវត្តកម្មវិធីជំនួយសង្គមក្នុងកញ្ចប់គ្រួសារ ខែធ្នូ ឆ្នាំ២០២៣ មាននៅ https://nspc.gov.kh/Images/៣៧២_អនក្របក_ការអនុវត្តកម្មវិធីជំនួយសង្គមក្នុងកញ្ចប់គ្រួសារ_2024_05_06_08_51_22.pdf (ជាភាសាខ្មែរ) និងអនុក្រឹត្យលេខ ៣៧១ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ ៨៨ ស្តីពីការអនុវត្តកម្មវិធីជំនួយជាសាច់ប្រាក់ក្នុងអំឡុងពេលប្រយុទ្ធនឹងជំងឺកូវីដ-១៩ ខែធ្នូ ឆ្នាំ២០២៣ មាននៅ https://nspc.gov.kh/Images/៣៧១_អនក្របក_កែសម្រួលអនុក្រឹត្យ៨៨អនក្របកឆ្នាំ២០២០កម្មវិធីឧបត្ថម្ភ_2024_01_11_15_07_12.pdf (ជាភាសាខ្មែរ). (សម្រាប់អនុក្រឹត្យលេខ ៨៨ សូមមើល https://nspc.gov.kh/Images/Sub%20Decree%20No%2088_2020_06_22_11_38_00.pdf).

[18] រាជរដ្ឋាភិបាលកម្ពុជា អនុក្រឹត្យលេខ ២៨០ ស្តីពីរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព តាមរបបភាគទានដោយស្ម័គ្រចិត្ត (ថ្ងៃទី២៨ ខែសីហា ឆ្នាំ២០២៣) មាននៅ https://data.opendevelopmentcambodia.net/laws_record/sub-decree-no-280-on-conditions-process-and-procedures-for-the-implementation-of-the-national-socia (ជាភាសាខ្មែរ).

[19] គណៈកម្មាធិការសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ មតិយោបល់ទូទៅ លេខ ១៩ (ឆ្នាំ២០០៧) កថាខណ្ឌទី២៥ និងអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ មាត្រា ១១ និង ១២.

ដែលផ្អែកលើការសម្ភាសអ្នកធ្វើការនៅក្នុងវិស័យក្រៅប្រព័ន្ធចំនួន ៤៥២ នាក់ (ស្ត្រី ២៧៦ នាក់ និងបុរស ១៧៦ នាក់) ដែលធ្វើឡើងដោយ OHCHR នៅខែមេសា និងឧសភា ឆ្នាំ២០២៣។ ការវាយតម្លៃបានបង្ហាញថា អ្នកឆ្លើយតប ៥៤ ភាគរយ មិនមានឆន្ទៈផ្តល់ភាគទានដល់ការធានារ៉ាប់រងសុខភាពនោះទេ ដោយក្នុងនោះ អ្នកឆ្លើយតប ៧០ ភាគរយ បានអះអាងថា ប្រាក់ចំណូលមិនគ្រប់គ្រាន់ ឬមិនទៀងទាត់ គឺជាមូលហេតុមួយក្នុងចំណោមមូលហេតុដទៃទៀត។ ការសម្ភាសនោះក៏បានបង្ហាញផងដែរថា កត្តាជាច្រើន រួមមាន ប្រាក់ចំណូល ទំហំគ្រួសារ និងមុខរបរ គួរតែត្រូវបានយកមកពិចារណា នៅពេលកំណត់ចំនួនទឹកប្រាក់ភាគទានរបស់បុគ្គលម្នាក់ៗចំពោះរបបគាំពារសង្គម។

# IV. សមភាព និង ការមិនរើសអើង

## ក. សមភាពយេនឌ័រ និងសិទ្ធិមនុស្សរបស់មនុស្សស្រីស្រលាញ់ភេទដូចគ្នា មនុស្សប្រុសស្រលាញ់ភេទដូចគ្នា មនុស្សស្រឡាញ់ភេទទាំងពីរ និងមនុស្សប្តូរភេទ

21. ដោយមានការសម្របសម្រួលជាមួយភ្នាក់ងារអង្គការសហប្រជាជាតិលើកកម្ពស់សមភាពយេនឌ័រ និងការផ្តល់ភាពអង់អាចដល់ស្ត្រី (UN-Women) និងមូលនិធិសហប្រជាជាតិសម្រាប់ប្រជាជន OHCHR បានបន្តសហការជាមួយក្រសួងកិច្ចការនារី ដើម្បីគាំទ្រដំណើរការវិសោធនកម្មច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះដោយអំពើហិង្សាក្នុងគ្រួសារ ស្របតាមអនុសាសន៍របស់គណៈកម្មាធិការស្តីពីការលុបបំបាត់ការរើសអើងប្រឆាំងនឹងនារីភេទ ឆ្នាំ២០១៩។[20]

22. នៅខែសីហា ឆ្នាំ២០២៣ OHCHR សហការជាមួយអង្គការមិនមែនរដ្ឋាភិបាល ដែលធ្វើការលើសិទ្ធិជនជាតិដើមភាគតិច និងសមភាពយេនឌ័រ បានផ្តល់ការបណ្តុះបណ្តាលកសាងសមត្ថភាពស្តីពីការពិនិត្យតាមដាន និងការរាយការណ៍អំពីអំពើហិង្សាផ្លូវភេទ និងអំពើហិង្សាយេនឌ័រ ដល់អ្នកការពារសិទ្ធិមនុស្ស ចំនួន ៣០ នាក់ (ស្ត្រី ២០ នាក់ និងបុរស ១០ នាក់) ដែលមកពីសហគមន៍ជនជាតិដើមភាគតិចចំនួនប្រាំបី។

23. ក្នុងភាពជាដៃគូជាមួយបណ្ឌិត្យសភាភូមិន្ទយុត្តិធម៌ OHCHR បានរៀបចំវគ្គបណ្តុះបណ្តាលសាកល្បង នៅខែតុលា ឆ្នាំ២០២៣ ក្រោមប្រធានបទ "ការដោះស្រាយភាពលម្អៀងនៃយេនឌ័រនៅក្នុងប្រព័ន្ធតុលាការ" ដោយមានអ្នកចូលរួមចំនួន ៣៥ នាក់ (ស្ត្រី ២១ នាក់ និងបុរស ១៤ នាក់) ដែលរួមមាន ចៅក្រម ព្រះរាជអាជ្ញា និងតំណាងក្រសួងយុត្តិធម៌ និងរាជបណ្ឌិត្យសភាផងដែរ។ OHCHR បានចូលរួមជាមួយរាជបណ្ឌិត្យសភា ក្នុងគោលបំណងបញ្ចូលវគ្គបណ្តុះបណ្តាលសាកល្បងនេះ និងវគ្គបណ្តុះបណ្តាលដទៃទៀតស្តីពីច្បាប់សិទ្ធិមនុស្សអន្តរជាតិនៅក្នុងកម្មវិធីសិក្សាផ្លូវការសម្រាប់ជំនាញវិជ្ជាជីវៈតុលាការ ដើម្បីធានាបាននូវភាពជាម្ចាស់ និងនិរន្តរភាពថ្នាក់ជាតិ។

24. នៅខណៈពេលដែលរដ្ឋាភិបាលបានចាត់វិធានការដើម្បីលើកកម្ពស់សិទ្ធិទទួលបានសមភាព និងការមិនរើសអើងចំពោះមនុស្សស្រីស្រឡាញ់ភេទដូចគ្នា មនុស្សប្រុសស្រឡាញ់ភេទដូចគ្នា មនុស្សស្រឡាញ់ភេទទាំងពីរ និងមនុស្សប្តូរភេទនោះ អវត្តមាននៃការទទួលស្គាល់គូស្នេហ៍ភេទដូចគ្នាតាមផ្លូវ

[20] CEDAW/C/KHM/CO/6 កថាខណ្ឌទី ២៥(ខ).

ច្បាប់ បានបន្តធ្វើឲ្យមានការផាត់ពួកគេចេញពីសង្គមកម្ពុជា។ OHCHR បានគាំទ្រការអំពាវនាវរបស់សហគមន៍មនុស្សស្រីស្រឡាញ់ភេទដូចគ្នា មនុស្សប្រុសស្រឡាញ់ភេទដូចគ្នា មនុស្សស្រឡាញ់ភេទទាំងពីរ និងមនុស្សប្តូរភេទ ក្នុងការធ្វើឱ្យអាពាហ៍ពិពាហ៍ភេទដូចគ្នាមានភាពស្របច្បាប់ និងការទទួលស្គាល់អត្តសញ្ញាណយេនឌ័រ ស្របតាមអនុសាសន៍ពីយន្តការសិទ្ធិមនុស្សអន្តរជាតិ រួមទាំងអនុសាសន៍ដែលប្រទេសកម្ពុជាបានទទួលយកក្នុងអំឡុងពេលនៃការត្រួតពិនិត្យតាមកាលកំណត់ជាសកលលើកទីបីផងដែរ។[21] នៅថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០២៣ OHCHR បានផ្តល់ការគាំទ្រដល់តំណាងសង្គមស៊ីវិលនៃមនុស្សស្រីស្រឡាញ់ភេទដូចគ្នា មនុស្សប្រុសស្រឡាញ់ភេទដូចគ្នា មនុស្សស្រឡាញ់ភេទទាំងពីរ និងមនុស្សប្តូរភេទ ក្នុងការរៀបចំកិច្ចសន្ទនាជាមួយរដ្ឋាភិបាល ដើម្បីកំណត់ជម្រើសក្នុងការជំរុញសមភាពអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់ ដែលមានអ្នកចូលរួមចំនួន ២១២ នាក់ រួមទាំងតំណាងរដ្ឋាភិបាល សង្គមស៊ីវិល និងអង្គភាពសហប្រជាជាតិ ព្រមទាំងមនុស្សស្រីស្រឡាញ់ភេទដូចគ្នា មនុស្សប្រុសស្រឡាញ់ភេទដូចគ្នា មនុស្សស្រឡាញ់ភេទទាំងពីរ និងមនុស្សប្តូរភេទ និងសមាជិកគ្រួសាររបស់ពួកគេផងដែរ។

## ខ. សិទ្ធិជនជាតិដើមភាគតិច

25. OHCHR បានបន្តបង្កើនការយល់ដឹងអំពីសិទ្ធិជនជាតិដើមភាគតិច ដើម្បីធានាបាននូវបរិយាប័ន្ន និងការចូលរួមរបស់ពួកគេនៅក្នុងដំណើរការនៃការសម្រេចចិត្ត ដែលប៉ះពាល់ដល់ពួកគេ ដោយមានការពិគ្រោះយោបល់ជាមួយតំណាងអង្គការជនជាតិដើមភាគតិច។ OHCHR ក៏បានផ្តល់ហិរញ្ញប្បទានឥតសំណងដល់អង្គការជនជាតិដើមភាគតិច ដើម្បីលើកកម្ពស់លទ្ធភាពទទួលបានយុត្តិធម៌សម្រាប់ស្ត្រី និងកុមារីជនជាតិដើមភាគតិច ដែលរួចផុតពីគ្រោះថ្នាក់នៃអំពើហិង្សាផ្លូវភេទ និងអំពើហិង្សាយេនឌ័រផងដែរ ធ្វើដូច្នេះ ដើម្បីធានាបាននូវសិទ្ធិទទួលបានឧបាស្រ័យ និងការប្រើប្រាស់ប្រព័ន្ធតុលាការសម្រាប់ជនដែលស្ថិតក្នុងស្ថានភាពងាយរងគ្រោះ។

26. នៅខែសីហា ឆ្នាំ២០២៣ OHCHR បានផ្តល់ការគាំទ្រដល់ក្រសួងអភិវឌ្ឍន៍ជនបទ និងសង្គមស៊ីវិល ក្នុងការប្រារព្ធទិវាអន្តរជាតិជនជាតិដើមភាគតិចពិភពលោក ដែលផ្តល់ឱកាសដល់ការលើកកម្ពស់ភាពជាដៃគូ និងការចូលរួមជាមួយភាគីពាក់ព័ន្ធ បង្កើនការយល់ដឹងអំពីសិទ្ធិជនជាតិដើមភាគតិច និងប្រយុទ្ធប្រឆាំងការរើសអើងចំពោះពួកគេ។

27. ក្រមបរិស្ថាន និងធនធានធម្មជាតិ ឆ្នាំ២០២៣ ត្រូវបានអនុម័តនៅថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២៣។ ក្រមនេះបានរួមបញ្ចូលផ្នែកធំៗនៃសេចក្តីព្រាងវិសោធនកម្មច្បាប់ស្តីពីតំបន់ការពារធម្មជាតិ ដែលក្រុមការងារប្រចាំប្រទេសរបស់អង្គការសហប្រជាជាតិបានផ្តល់ដំបូន្មានផ្នែកបច្ចេកទេស កាលពីខែមេសា ឆ្នាំ២០២៣។ ទោះបីជាយ៉ាងណាក៏ដោយ ដំបូន្មានទាំងនោះមិនត្រូវបានឆ្លុះបញ្ចាំងនៅក្នុងក្រមនេះទេ ជាលទ្ធផល មានកង្វះខាតឯកសារយោងអំពីជនជាតិដើមភាគតិច និងមិនមានការទទួលស្គាល់យ៉ាងច្បាស់លាស់អំពីទំនៀមទម្លាប់ ប្រពៃណី និងប្រព័ន្ធកាន់កាប់ដីធ្លីរបស់ពួកគេនោះទេ។

[21] សូមមើល A/HRC/56/49/Add.2 កថាខណ្ឌទី ៦៧ ៦៨ ៧១(គ) និង ៧២ ផងដែរ។

## គ. សិទ្ធិជនមានពិការភាព

28. ជាផ្នែកមួយនៃកម្មវិធីរួមគ្នាពន្លឿនសិទ្ធិជនមានពិការភាពនៅកម្ពុជា[22] OHCHR បានបន្តចូលរួមជាមួយក្រុមប្រឹក្សាសកម្មភាពជនពិការ[23] និងអង្គការជនពិការ ដើម្បីលើកកម្ពស់អភិក្រមផ្អែកលើសិទ្ធិមនុស្សចំពោះពិការភាព។ OHCHR បានផ្តល់ជំនាញបច្ចេកទេសលើការវាយតម្លៃការអនុវត្តផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព លើកទីពីរ ឆ្នាំ២០១៩-២០២៣ និងការអភិវឌ្ឍផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព លើកទីបី ឆ្នាំ២០២៤-២០២៨ (រំពឹងថានឹងអនុម័តនៅឆ្នាំ២០២៤) រួមទាំង តាមរយៈការពិគ្រោះយោបល់ជាមួយអង្គការជនពិការ និងភាគីពាក់ព័ន្ធដទៃទៀតដែរ។ OHCHR បានបន្តផ្តល់ដំបូន្មានផ្នែកបច្ចេកទេសដល់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា លើសេចក្តីព្រាងច្បាប់ស្តីពីកិច្ចការពារសិទ្ធិជនពិការ ដែលរង់ចាំសេចក្តីសម្រេច រួមទាំងសិទ្ធិរបស់ជនមានពិការភាពផ្នែកចិត្តសាស្ត្រសង្គម ស្របតាមច្បាប់សិទ្ធិមនុស្សអន្តរជាតិ។

29. នៅខែតុលា និងខែវិច្ឆិកា ឆ្នាំ២០២៣ OHCHR និងក្រុមប្រឹក្សាសកម្មភាពជនពិការបានសហការរៀបចំកម្មវិធីបណ្តុះបណ្តាលចំនួនពីរ ស្តីពីលទ្ធភាពទទួលបានយុត្តិធម៌របស់ជនពិការ ដើម្បីកសាងសមត្ថភាពអ្នកវិជ្ជាជីវៈតុលាកា ចំនួន ១២១ នាក់ (ស្ត្រី ៣៤ នាក់ និង បុរស ៨៧ នាក់) មកពីខេត្តចំនួនប្រាំបី នៅទូទាំងប្រទេសកម្ពុជា ដោយមានអង្គការជនពិការជាអ្នកសហការផ្តល់ការបណ្តុះបណ្តាល។ OHCHR ក៏បានផ្តល់ការគាំទ្រដល់ក្រុមប្រឹក្សាក្នុងការបញ្ចប់របាយការណ៍លើកដំបូងរបស់រដ្ឋភាគីស្តីពីការអនុវត្តអនុសញ្ញាស្តីពីសិទ្ធិជនពិការ ដែលដល់កំណត់ក្នុងខែមករា ឆ្នាំ២០១៥ រួមទាំងការរៀបចំវគ្គបណ្តុះបណ្តាលស្តីពីបទដ្ឋាន និងការរាយការណ៍ក្រោមអនុសញ្ញានេះ នៅក្នុងកម្មវិធីកសាងសមត្ថភាពស្ថាប័នសន្ធិសញ្ញារបស់ OHCHR ក្នុងខែកុម្ភៈ ឆ្នាំ២០២៤ សម្រាប់ក្រុមប្រឹក្សានេះផងដែរ។ រដ្ឋាភិបាលបានជូនដំណឹងដល់ OHCHR ថា ខ្លួនមានបំណងផ្តល់អាទិភាពដល់ការដាក់ជូនរបាយការណ៍នោះនៅឆ្នាំ២០២៤។

30. OHCHR បានបន្តផ្តល់ការគាំទ្រដល់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងក្រុមប្រឹក្សាសកម្មភាពជនពិការ ក្នុងការលើកកម្ពស់ការយល់ដឹងអំពីសិទ្ធិជនពិការ រួមទាំងព្រឹត្តិការណ៍នានា ដើម្បីប្រារព្ធសប្តាហ៍មនុស្សថ្លង់ជាតិ ក្នុងខែកញ្ញា ឆ្នាំ២០២៣ (មានអ្នកចូលរួមចំនួន ៤00 នាក់ រួមទាំងសិស្សដែលមានការចុះខ្សោយការស្តាប់ចំនួន ២00 នាក់ ផងដែរ) ទិវាជនពិការអន្តរជាតិ នៅខែធ្នូ ឆ្នាំ២០២៣ និងទិវាយល់ដឹងអំពីជំងឺអូទីសឹមពិភពលោក និងទិវាជំងឺដោនស៊ីនដ្រូមពិភពលោក នៅខែមេសា ឆ្នាំ២០២៤។

31. OHCHR និងក្រុមប្រឹក្សាសកម្មភាពជនពិការ ក៏បានសហការផលិតយុទ្ធនាការខ្សែភាពយន្តមួយក្រោមចំណងជើងថា "សិទ្ធិរបស់ខ្ញុំ ជីវិតរបស់ខ្ញុំ" នៅខែធ្នូ ឆ្នាំ២០២៣ ដែលបង្ហាញពីសាច់រឿងប្រកបដោយការបំផុសគំនិតរបស់ជនពិការ សំដៅលើកកម្ពស់សិទ្ធិមនុស្សរបស់ពួកគេ និងជះឥទ្ធិពលលើការ

[22] សម្រាប់ព័ត៌មានបន្ថែម សូមមើល https://unprpd.org/programme/cambodia-2/។

[23] នេះគឺជាយន្តការសម្របសម្រួល និងផ្តល់ដំបូន្មានថ្នាក់ជាតិលើបញ្ហាពិការភាពនៅកម្ពុជា។

យល់ឃើញដែលអ្នកដទៃមានចំពោះពួកគេ នៅក្នុងសង្គម។[24] ដើម្បីរំឭកដល់ទិវាជនពិការអន្តរជាតិ នៅថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០២៣ OHCHR បានផ្សព្វផ្សាយយុទ្ធនាការខ្សែភាពយន្ត នៅលើប្រព័ន្ធផ្សព្វផ្សាយសង្គម ហើយក្រុមប្រឹក្សាសកម្មភាពជនពិការក៏បានបង្ហាញខ្សែភាពយន្តនេះនៅក្នុងព្រឹត្តិការណ៍មួយ ដែលក្រុមប្រឹក្សានេះបានរៀបចំឡើង ដោយមានអ្នកចូលរួមចំនួន ៣.៧៥០ នាក់ រួមទាំងជនពិការប្រហែល ២.៧៣០ នាក់ផងដែរ។

## V. ការចូលរួមជាសាធារណៈ និង លំហពលរដ្ឋ

32. មុនពេលឈានដល់ការបោះឆ្នោតថ្នាក់ជាតិ នៅថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២៣ និងការបោះឆ្នោតព្រឹទ្ធសភា នៅថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០២៤ OHCHR បានធ្វើបេសកកម្មចំនួន ១៣ ទៅកាន់ ២២ ខេត្តនៅក្នុងប្រទេស។ OHCHR បានចងក្រងឯកសារអំពីករណីគំរាមកំហែង និងការបំភិតបំភ័យសង្គមស៊ីវិល និងតួអង្គនយោបាយនានា និងបានទទួលរបាយការណ៍ចោទប្រកាន់អំពីការរំលោភលើរាងកាយរបស់តួអង្គប្រឆាំងផ្នែកនយោបាយ ដោយជនមិនស្គាល់មុខផងដែរ។ ជនរងគ្រោះបានកត់សម្គាល់ថាពួកគេជឿជាក់ថា ពួកគេត្រូវបានគេកំណត់មុខសញ្ញារួចហើយ ពីព្រោះពួកគេមានទំនាក់ទំនងជាមួយគណបក្សប្រឆាំង ដោយជនរងគ្រោះជាច្រើននាក់បានអះអាងថា ពួកគេបានស្ថិតក្រោមការឃ្លាំមើលពីជនមិនស្គាល់មុខ កាលពីប៉ុន្មានថ្ងៃមុនពេលដែលពួកគេទទួលរងការវាយប្រហារ។ OHCHR ក៏បានចងក្រងឯកសារអំពីករណីចាប់ខ្លួន និងការកាត់ទោសជនដែលមានទំនាក់ទំនងជាមួយគណបក្សប្រឆាំង រួមទាំងការអនុវត្តសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិរបស់ពួកគេផងដែរ។ លើសពីនេះទៀត គណបក្សភ្លើងទៀន មិនបានចុះបញ្ជីសម្រាប់ការបោះឆ្នោតព្រឹទ្ធសភាទេ ពីព្រោះគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតបានបដិសេធមិនចុះបញ្ជីគណបក្សនេះនៅក្នុងការបោះឆ្នោតថ្នាក់ជាតិ ដោយអះអាងថាគណបក្សនេះមិនបានផ្តល់ច្បាប់ចម្លង "ដែលមានការបញ្ជាក់" នៃឯកសារចុះបញ្ជីច្បាប់ដើម។

33. នៅថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០២៣ រដ្ឋាភិបាលបានប្រកាសឱ្យប្រើវិសោធនកម្មច្បាប់បោះឆ្នោតជាច្រើនច្បាប់ រួមទាំងច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រផងដែរ បន្ទាប់ពីបានដំណើរការអស់រយៈពេលមួយខែ ដោយបានចាប់ផ្តើមមុនពេលបោះឆ្នោតថ្នាក់ជាតិ ដែលបានរាយការណ៍ថាមានកង្វះខាតការពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធទាំងអស់។ ក្នុងចំណោមចំណុចផ្សេងទៀត វិសោធនកម្មទាំងនេះបានណែនាំអំពីការផាកពិន័យ និងការហាមឃាត់ប្រជាពលរដ្ឋ និងគណបក្សនយោបាយ ដែលនឹងរារាំងពួកគេមិនឱ្យឈរឈ្មោះបោះឆ្នោត និងចូលរួមបោះឆ្នោតយ៉ាងតិចប្រាំឆ្នាំ ប្រសិនបើពួកគេបានប្រព្រឹត្តិនូវទង្វើមួយចំនួន ដូចជា ការណែនាំ ឬញុះញង់អ្នកបោះឆ្នោតឱ្យបំផ្លាញ ឬធ្វើឱ្យខូចសន្លឹកឆ្នោតរបស់ពួកគេ រារាំងជនដែលមានសិទ្ធិបោះឆ្នោតមិនឲ្យចូលរួមបោះឆ្នោត ឬញុះញង់ពួកគេមិនឱ្យបោះឆ្នោត ឬអនុញ្ញាតឱ្យអ្នកគាំទ្រចូលរួមគំរាមកំហែង ឬប្រើអំពើហិង្សាលើបេក្ខជន ឬគណបក្សនយោបាយដទៃទៀត។ នៅថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២៣ ឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សបានបង្ហាញនូវកង្វល់ថា វិសោធនកម្មទាំងនេះ ប្រសិនបើត្រូវ

[24] សូមមើល https://www.facebook.com/OHCHRCambodia/videos/226232520502340.

បានអនុម័ត នឹងរឹតត្បិតសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ និងសិទ្ធិឈរឈ្មោះបោះឆ្នោត។[25]

34. នៅមួយសប្តាហ៍មុនពេលបោះឆ្នោតថ្នាក់ជាតិ សកម្មជនគណបក្សភ្លើងទៀនចំនួនបួនរូប រួមទាំងលោក អេង ស្រ៊ុយ (ប្រធានគណបក្សភ្លើងទៀនខេត្តត្បូងឃ្មុំ) ផងដែរ ត្រូវបានចាប់ខ្លួន និងមានការរាយការណ៍ថា ត្រូវបានចោទប្រកាន់ពីបទ "ញុះញង់ឲ្យប្រព្រឹត្តបទឧក្រិដ្ឋ ឬរំខានដល់សន្តិសុខសង្គម" យោងតាមមាត្រា ៤៩៤ និង ៤៩៥ នៃក្រមព្រហ្មទណ្ឌ។ មានការរាយការណ៍ថា ពួកគេត្រូវបានចោទប្រកាន់ពីបទញុះញង់ប្រជាជនឱ្យធ្វើឲ្យខូចសន្លឹកឆ្នោត និងរំខានដល់ដំណើរការបោះឆ្នោត ពាក់ព័ន្ធនឹងសមាជិកភាពរបស់ពួកគេនៅក្នុងក្រុមហ្វេសប៊ុកសាធារណៈមួយ ដែលព្រះរាជអាជ្ញាបានចោទប្រកាន់ថា ត្រូវបានបង្កើតឡើងដើម្បីរំខានដល់ការបោះឆ្នោត។ នៅថ្ងៃទី២០ ខែសីហា ឆ្នាំ២០២៣ អនុប្រធានគណបក្សភ្លើងទៀនខេត្តត្បូងឃ្មុំ ត្រូវបានចាប់ខ្លួន ពាក់ព័ន្ធករណីដូចគ្នានេះ។ នៅខណៈពេលដែលលោក ស្រ៊ុយ ស្ថិតក្នុងការឃុំខ្លួននៅឡើយ សហចុងចោទចំនួនបួនរូបផ្សេងទៀតត្រូវបានដោះលែងឱ្យនៅក្រៅឃុំ កាលពីខែតុលា ឆ្នាំ២០២៣ បន្ទាប់ពីមានការសុំទោសជាសាធារណៈទៅកាន់រដ្ឋាភិបាល និងចាកចេញពីគណបក្សភ្លើងទៀន ទៅចូលរួមជាមួយគណបក្សប្រជាជនកម្ពុជា។ នៅពេលបញ្ចប់រយៈពេលធ្វើរបាយការណ៍នេះ សហចុងចោទទាំងប្រាំរូបនៅតែរង់ចាំសេចក្តីសម្រេចពីសាលាដំបូង។

35. នៅថ្ងៃបោះឆ្នោតថ្នាក់ជាតិ ថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២៣ លោក ថៅ វាសនា ប្រធានគណបក្សភ្លើងទៀន ក្រុងប៉ោយប៉ែត ត្រូវបានចាប់ខ្លួន និងចោទប្រកាន់ពីបទ "ញុះញង់ឲ្យប្រព្រឹត្តបទឧក្រិដ្ឋ ឬរំខានដល់សន្តិសុខសង្គម" យោងតាមមាត្រា៤៩៤ និង ៤៩៥ នៃក្រមព្រហ្មទណ្ឌ ទាក់ទងនឹងការមានឈ្មោះនៅក្នុងបញ្ជីឈ្មោះបុគ្គល ៤០ នាក់ ដែលត្រូវបានរាយការណ៍ដោយប្រព័ន្ធផ្សព្វផ្សាយក្នុងស្រុកថា ត្រូវបានចោទប្រកាន់ពីបទញុះញង់អ្នកបោះឆ្នោតឱ្យធ្វើខូចសន្លឹកឆ្នោតរបស់ពួកគេ។ នៅថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០២៤ លោក វាសនា ត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគាររយៈពេលបីឆ្នាំ ហាមមិនឲ្យបោះឆ្នោត ឬឈរឈ្មោះបោះឆ្នោតរយៈពេលប្រាំឆ្នាំ និងបង្គាប់ឱ្យផ្តល់សំណងដល់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។

36. ក្នុងអំឡុងពេលធ្វើរបាយការណ៍នេះ OHCHR បានពិនិត្យតាមដានការបើកសវនាការចំនួន ២៨ លើក ក្នុងការកាត់ទោសព្រហ្មទណ្ឌលើអ្នកការពារសិទ្ធិមនុស្ស អ្នកសារព័ត៌មាន និងតួអង្គនយោបាយ។ នៅខែមករា ឆ្នាំ២០២៤ សាលាឧទ្ធរណ៍បានចាប់ផ្តើមបើកសវនាការលើបណ្តឹងឧទ្ធរណ៍របស់លោក កឹម សុខា អតីតប្រធានគណបក្សសង្គ្រោះជាតិ ដែលបច្ចុប្បន្នត្រូវបានរំលាយ។ សាលាដំបូងរាជធានីភ្នំពេញបានសម្រេចកាត់ទោសលោក កឹម សុខា (ដែលត្រូវបានឃុំខ្លួនក្នុងផ្ទះតាំងពីខែមីនា ឆ្នាំ២០២៣ ដោយហេតុផលផ្នែកសុខភាព) និងផ្តន្ទាទោសដាក់ពន្ធនាគាររយៈពេល ២៧ ឆ្នាំ ពីបទ "ក្បត់ជាតិ និងចារកម្ម" និង "ឃុបឃិតជាមួយបរទេស" យោងតាមមាត្រា ៤៣៩ និង ៤៤៣ នៃក្រមព្រហ្មទណ្ឌ សម្រាប់ការថ្លែងសុន្ទរកថា នៅប្រទេសអូស្ត្រាលី ក្នុងឆ្នាំ២០១៣ ដែលគាត់បាននិយាយអំពីលទ្ធិប្រជាធិបតេយ្យនៅថ្នាក់មូលដ្ឋាន។ សាលាឧទ្ធរណ៍បានសម្រេចថា មេធាវីរបស់គាត់នៅតែត្រូវស្នើសុំការអនុញ្ញាតពីព្រះរាជអាជ្ញានៃសាលាដំបូងរាជធានីភ្នំពេញជាមុនសិន ទើបអាចចូលជួបកូនក្តីរបស់ពួកគេបាន។

[25] សូមមើល https://www.ohchr.org/en/press-briefing-notes/2023/06/cambodia-turk-urges-new-course-ensure-free-and-fair-vote.

37. នៅថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០២៣ សាលាដំបូងរាជធានីភ្នំពេញ បានកាត់ទោសលោក ថាច់ សេដ្ឋា អនុប្រធានគណបក្សភ្លើងទៀន ដែលត្រូវបានចាប់ខ្លួនកាលពីខែមករា ឆ្នាំ២០២៣ ពីបទរំលោភលើមាត្រា២៣១ នៃច្បាប់ស្តីពីឧបករណ៍អាចជួញដូរបាន និងប្រតិបត្តិការទូទាត់ប្រាក់។ នៅថ្ងៃទី១៨ ខែតុលា ឆ្នាំ២០២៣ តុលាការបានកាត់ទោសលោក សេដ្ឋា ពីបទ "ញុះញង់ឲ្យប្រព្រឹត្តបទឧក្រិដ្ឋ ឬរំខានដល់សន្តិសុខសង្គម" និង "ការរើសអើង" យោងតាមមាត្រា ៤៩៤ ៤៩៥ និង ៤៩៦ នៃក្រមព្រហ្មទណ្ឌ ពាក់ព័ន្ធនឹងកិច្ចប្រជុំដែលលោកបានធ្វើឡើងជាមួយកម្មករទេសន្តរប្រវេសន៍កម្ពុជានៅសាធារណរដ្ឋកូរ៉េកាលពីខែមករា ឆ្នាំ២០២៣ ដើម្បីទទួលបានការគាំទ្រជូនគណបក្សភ្លើងទៀន។ ការចោទប្រកាន់ទាំងនេះត្រូវបានធ្វើឡើងចំពោះគាត់ ក្នុងខែមេសា ឆ្នាំ២០២៣ មុនពេលបញ្ចប់រយៈពេលអតិបរមានៃការឃុំខ្លួនបណ្ដោះអាសន្នរបស់គាត់ ពាក់ព័ន្ធនឹងការចោទប្រកាន់លើកដំបូង ពាក់ព័ន្ធនឹងឧបករណ៍ដែលអាចជួញដូរបាន។ ទាក់ទងនឹងការកាត់ទោសសម្រាប់បទល្មើសទាំងពីរនេះ សាលាដំបូងរាជធានីភ្នំពេញបានផ្តន្ទាទោសដាក់ពន្ធនាគារ លោក សេដ្ឋា រយៈពេលបួនឆ្នាំកន្លះ។ នៅខែមករា ឆ្នាំ២០២៤ និងខែកុម្ភៈ ឆ្នាំ២០២៤ សាលាឧទ្ធរណ៍បានសម្រេចតម្កល់សាលក្រមនៃបទល្មើសទាំងពីរទុកជាបានការ ហើយលោក សេដ្ឋា បានប្តឹងឧទ្ធរណ៍លើសំណុំរឿងទាំងពីរនេះទៅកាន់តុលាការកំពូល។

38. កាលពីថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០២៤ លោក ឈន ផល្លា សកម្មជនបរិស្ថានក្នុងស្រុក ត្រូវបានកាត់ទោស ពិន័យ និងផ្តន្ទាទោសដោយកំបាំងមុខ ឲ្យជាប់ពន្ធនាគាររយៈពេលមួយឆ្នាំ ពីបទ "បរិហារកេរ្តិ៍ជាសាធារណៈ" "ញុះញង់ឲ្យមានការរើសអើង" និង "ប្រមាថ" យោងតាមមាត្រា ៣០៥ ៤៩៥ និង ៥០២ នៃក្រមព្រហ្មទណ្ឌ ទាក់ទងនឹងសេចក្តីថ្លែងការណ៍ជាសាធារណៈ ដែលគាត់បានធ្វើឡើងកាលពីឆ្នាំ២០២០ ដែលរិះគន់អាជ្ញាធរមូលដ្ឋាន ចំពោះការខកខានមិនបានការពារតំបន់មួយពីការកាប់បំផ្លាញព្រៃឈើ។ នៅខែតុលា ឆ្នាំ២០២៣ សាលាឧទ្ធរណ៍បានច្រានចោលសាលក្រមកាត់ទោស និងផ្តន្ទាទោសគាត់ ក្នុងឆ្នាំ២០២១ ពីបទកាប់រានដីព្រៃ ជាលទ្ធផល គាត់ត្រូវបានដោះលែងខ្លួន បន្ទាប់ពីបានអនុវត្តទោសជាប់ពន្ធនាគាររយៈពេលពីរឆ្នាំ នៃការផ្តន្ទាទោសរយៈពេលប្រាំមួយឆ្នាំ។

39. នៅថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០២៣ លោក កង សារ៉ាន់ ត្រូវបានឃុំខ្លួន បន្ទាប់ពីរងការចោទប្រកាន់ពីបទ "ប្រមាថជាសាធារណៈ" និង "ញុះញង់ឲ្យប្រព្រឹត្តបទឧក្រិដ្ឋ ឬរំខានដល់សន្តិសុខសង្គម" យោងតាមមាត្រា ៣០៧ ៤៩៤ និង ៤៩៥ នៃក្រមព្រហ្មទណ្ឌ ពាក់ព័ន្ធនឹងវីដេអូនៅក្នុងប្រព័ន្ធផ្សព្វផ្សាយសង្គម ដែលលោកបានបង្ហោះទាមទារឲ្យមានការពន្យល់ថាតើគណបក្សប្រជាជនកម្ពុជានឹងបណ្តេញជនអន្តោប្រវេសន៍វៀតណាមចេញពីប្រទេស ឬនាំចូលមកក្នុងប្រទេសបន្ថែមទៀត ប្រសិនបើខ្លួនឈ្នះការបោះឆ្នោតថ្នាក់ជាតិ។ លោក សារ៉ាន់ ក៏បានរងការចោទប្រកាន់ពីបទប្រមាថព្រះមហាក្សត្រផងដែរ យោងតាមមាត្រា ៤៣៧ (ស្ទួន) នៃក្រមព្រហ្មទណ្ឌ ពាក់ព័ន្ធនឹងការចែករំលែកវីដេអូនៅលើ TikTok កាលពីខែមិថុនា ឆ្នាំ២០២៣ ដែលដំបូងឡើយ ត្រូវបានព្រះសង្ឃមួយអង្គបង្ហោះរិះគន់ព្រះមហាក្សត្រ។ នៅថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០២៣ សាលាដំបូងខេត្តបន្ទាយមានជ័យបានកាត់ទោសលោក សារ៉ាន់ និងផ្តន្ទាទោសដាក់ពន្ធនាគាររយៈពេលបីឆ្នាំ ហើយសាលាឧទ្ធរណ៍ខេត្តបាត់ដំបងបានតម្កល់សាលក្រមនេះទុកជាបានការ នៅថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២៤។

40. នៅថ្ងៃទី០៥ ខែមករា ឆ្នាំ២០២៤ លោក នី ណាក់ អ្នកអធិប្បាយពីបញ្ហាសង្គម ត្រូវបានឃុំខ្លួន និងរងការចោទប្រកាន់ពី "ការមិនរាងចាលក្នុងបទមជ្ឈិម" "បទបរិហារកេរ្តិ៍" "ការញុះញង់ឱ្យប្រព្រឹត្តបទឧក្រិដ្ឋ ឬរំខានដល់សន្តិសុខសង្គម" និង "ញុះញង់ឱ្យមានការរើសអើង" យោងតាមមាត្រា ៨៨ ៣០២ ៤៩៤ ៤៩៥ និង ៤៩៦ នៃក្រមព្រហ្មទណ្ឌ ទាក់ទងនឹងការបង្ហោះសារនៅលើប្រព័ន្ធផ្សព្វផ្សាយសង្គម ដែលលោកបានរិះគន់លើការចោទប្រកាន់មួយ ដែលបានធ្វើឡើងនៅក្នុងអត្ថបទសារព័ត៌មានមួយ ទាក់ទងនឹងការផ្តល់ដីធ្លីដោយរដ្ឋាភិបាល ដល់បុគ្គលម្នាក់ឈ្មោះ ហេង សួរ ដោយឈ្មោះនេះក៏ជាឈ្មោះរបស់រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈដែរ។ អ្នកនាំពាក្យព្រះរាជអាជ្ញាសាធារណៈបានចោទប្រកាន់ថា ការបង្ហោះសារតាមប្រព័ន្ធផ្សព្វផ្សាយសង្គមរបស់គាត់ មានព័ត៌មានមិនពិត ដែលប៉ះពាល់ដល់កេរ្តិ៍ឈ្មោះរបស់រដ្ឋមន្ត្រីរូបនោះ។ ទោះបីជាក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបានបញ្ជាក់ជាបន្តបន្ទាប់ថា ការចោទប្រកាន់នេះពាក់ព័ន្ធនឹង "ហេង សួរ" ម្នាក់ផ្សេងទៀតក៏ដោយ ក៏សំណើសុំនៅក្រៅឃុំរបស់លោក ណាក់ ត្រូវបានបដិសេធ កាលពីខែមីនា ឆ្នាំ២០២៤។

41. នៅថ្ងៃទី០៥ ខែមេសា ឆ្នាំ២០២៤ លោក កើត សារ៉ាយ ប្រធានសមាគមសម្ព័ន្ធនិស្សិតបញ្ញវន្តខ្មែរ ត្រូវបានចាប់ខ្លួន និងចោទប្រកាន់ពី "ការមិនរាងចាលក្នុងបទមជ្ឈិម" និង "បទញុះញង់ឲ្យប្រព្រឹត្តបទឧក្រិដ្ឋ ឬរំខានដល់សន្តិសុខសង្គម" យោងតាមមាត្រា ៨៨ ៤៩៤ និង ៤៩៥ នៃក្រមព្រហ្មទណ្ឌ។ លោក សារ៉ាយ បានរងការចោទប្រកាន់ថា បានញុះញង់អ្នកភូមិឲ្យតវ៉ាប្រឆាំងនឹងរដ្ឋាភិបាល។ អ្នកភូមិត្រូវបានបណ្តេញចេញដោយអាជ្ញាធរខេត្ត នៅក្នុងជម្លោះដីធ្លីនៅខេត្តព្រះវិហារ កាលពីថ្ងៃទី០៦ ខែមីនា ឆ្នាំ២០២៤ ហើយក្នុងនោះ មានអ្នកភូមិយ៉ាងតិច ២៨ នាក់ បានរងការចោទប្រកាន់ពីបទកាប់ទន្រ្ទាន និងហ៊ុមព័ទ្ធដីព្រៃ ដើម្បីទាមទារកម្មសិទ្ធិ។ គាត់ក៏បានរងការចោទប្រកាន់ពីការផ្តល់បទសម្ភាសតាមប្រព័ន្ធផ្សព្វផ្សាយ ថាប៉ុនប៉ងបង្កឱ្យមានការយល់ច្រឡំជាសាធារណៈចំពោះសកម្មភាពរបស់រដ្ឋាភិបាលផងដែរ។

42. ក្នុងអំឡុងពេលធ្វើរបាយការណ៍នេះ OHCHR បានចងក្រងឯកសារនៃបាតុកម្មយ៉ាងតិច ៩៥ លើក ដែលក្នុងនោះ ៧២ លើក ពាក់ព័ន្ធនឹងការតវ៉ាដែលធ្វើឡើងដោយសហជីពទ្រទ្រង់សិទ្ធិការងារបុគ្គលិកកម្មករខ្មែរនៅក្រុមហ៊ុនណាហ្គាវើលដ៍ (ករណីបនល្បែងណាហ្គាវើល ដែលបាន និងកំពុងបន្តកើតឡើងអស់រយៈពេលបីឆ្នាំមកហើយ ដោយមិនមានដំណោះស្រាយ)។ នៅថ្ងៃទី១៦ ខែតុលា ឆ្នាំ២០២៣ សាលាឧទ្ធរណ៍បានតម្កល់សាលក្រមកាលពីខែឧសភា ឆ្នាំ២០២៣ ស្តីពីការផ្តន្ទាទោសសកម្មជនសហជីពចំនួន ៩ រូប រួមទាំង កញ្ញា ឈឹម ស៊ីថរ ប្រធានសហជីពទ្រទ្រង់សិទ្ធិការងារ ពីបទ "ញុះញង់ឱ្យបង្កការរំខានដល់សន្តិសុខសង្គម" យោងតាមមាត្រា ៤៩៤ និង ៤៩៥ នៃក្រមព្រហ្មទណ្ឌ។ នៅថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០២៤ តុលាការកំពូលបានតម្កល់ការផ្តន្ទាទោសពួកគេ។ នៅថ្ងៃដដែលនោះ OHCHR បានសម្តែងការព្រួយបារម្ភជាសាធារណៈចំពោះការធ្វើសម្រេចតម្កល់ការផ្តន្ទាទោស កញ្ញា ស៊ីថរ ចំពោះការអនុវត្តសិទ្ធិក្នុងការជួបជុំដោយសន្តិវិធី និងសេរីភាពក្នុងការបង្កើតសមាគម និងបានអំពាវនាវឱ្យមានការដោះលែងគាត់ជាបន្ទាន់ ព្រមទាំងលុបចោលការផ្តន្ទាទោសទាំងអស់ផងដែរ។[26]

[26] សូមមើល https://www.ohchr.org/en/statements/2024/05/comment-un-human-rights-office-spokesperson-jeremy-laurence-

43. OHCHR បានបន្តទទួលពាក្យបណ្ដឹងអំពីការជ្រៀតជ្រែកក្នុងកិច្ចការតុលាការ ការចាប់ពិរុទ្ធ និងទម្រង់ដទៃទៀតនៃការបំភិតបំភ័យអ្នកសារព័ត៌មាន និងបុគ្គលិកប្រព័ន្ធផ្សព្វផ្សាយ ដែលបណ្ដាលឱ្យមានការចាប់ពិរុទ្ធខ្លួនឯង និងការរឹតត្បិតសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ។ នៅថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០២៣ និយ័តករទូរគមនាគមន៍កម្ពុជា ផ្អែកតាមបទបញ្ជារបស់ក្រសួងព័ត៌មានកាលពីមួយថ្ងៃមុន បានចេញលិខិតជូនដំណឹងទៅកាន់ក្រុមហ៊ុនផ្ដល់សេវាអ៊ីនធឺណិត ឱ្យបិទគណនីប្រព័ន្ធផ្សព្វផ្សាយសង្គមចំនួនប្រាំបួន និងគេហទំព័ររបស់បណ្ដាញសង្គមចំនួនបី ដើម្បីទប់ស្កាត់ការផ្សព្វផ្សាយព័ត៌មានមិនពិតដែលអាចបំផ្លាញដល់កេរ្តិ៍ឈ្មោះរបស់ប្រទេសកម្ពុជា។ បណ្ដាញសង្គមដែលរងផលប៉ះពាល់គឺជាប្រភពព័ត៌មានឯករាជ្យមួយចំនួនដែលនៅសេសសល់ នៅក្នុងប្រទេសកម្ពុជា ក្រោយពេលបិទវិទ្យុសំឡេងប្រជាធិបតេយ្យ កាលពីខែកុម្ភៈ ឆ្នាំ២០២៣។ នៅថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០២៣ ឧត្ដមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សបានសម្ដែងការព្រួយបារម្ភជាសាធារណៈដែលគណនីប្រព័ន្ធផ្សព្វផ្សាយរបស់បណ្ដាញសង្គមទាំងបីត្រូវបានបិទមុនពេលបោះឆ្នោតថ្នាក់ជាតិបន្តិច។[27]

44. ដើម្បីរំឭកដល់ទិវាអន្តរជាតិបញ្ចប់និទណ្ឌភាពលើឧក្រិដ្ឋកម្មប្រឆាំងអ្នកសារព័ត៌មាន នៅថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០២៣ OHCHR និងអង្គការអប់រំ វិទ្យាសាស្ត្រ និងវប្បធម៌របស់អង្គការសហប្រជាជាតិ (យូណេស្កូ) បានសហការគ្នារៀបចំការពិគ្រោះយោបល់ពហុភាគីស្ដីពីការអនុវត្តស្តង់ដារសិទ្ធិមនុស្សចំពោះសេរីភាពសារព័ត៌មាន ដែលបានផ្ដល់វេទិកាមួយដល់តំណាងរដ្ឋាភិបាលជាង ១៥០ នាក់ និងភាគីពាក់ព័ន្ធ ក្នុងការពិភាក្សាអំពីឧបសគ្គ និងឱកាសក្នុងការប្រកាន់ខ្ជាប់នូវសេរីភាពសារព័ត៌មាននៅក្នុងប្រទេសកម្ពុជា ស្របតាមនិយាម និងស្តង់ដារសិទ្ធិមនុស្សអន្តរជាតិ។[28]

45. ចាប់ពីថ្ងៃទី២៥ ខែមីនា ដល់ ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២៤ ក្រសួងមហាផ្ទៃបានធ្វើជំរឿនសមាគម និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ដែលបានចុះបញ្ជីរួចហើយ។ យោងតាមច្បាប់ស្ដីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល អង្គការដែលបានចុះបញ្ជីនៅក្រសួងមហាផ្ទៃត្រូវតែរាយការណ៍អំពីប្រតិបត្តិការ និងហិរញ្ញវត្ថុរបស់ពួកគេ និងការផ្លាស់ប្ដូរ ទាក់ទងនឹងការគ្រប់គ្រង ផ្នែករដ្ឋបាល និងព័ត៌មានធនាគាររបស់ពួកគេជារៀងរាល់ឆ្នាំ។ ទោះបីជាយ៉ាងណាក៏ដោយ OHCHR បានចងក្រងឯកសារអំពីករណីដែលអាជ្ញាធរមូលដ្ឋានបានដាក់លក្ខខណ្ឌតម្រូវខុសៗគ្នាលើអង្គការក្នុងស្រុក លើសពីអ្វីដែលច្បាប់តម្រូវ ដូចជា ការតម្រូវឱ្យអង្គការបំពេញទម្រង់បែបបទមួយ ដែលស្នើសុំអាសយដ្ឋានរបស់បុគ្គលិកម្នាក់ៗ។ ទម្រង់បែបបទនេះក៏រួមបញ្ចូលផ្នែកមួយ ដែលអាជ្ញាធរបានកត់សម្គាល់អំពីទស្សនៈផ្នែកនយោបាយរបស់អង្គការនីមួយៗផងដែរ។

46. នៅក្នុងទស្សនៈរបស់ខ្លួន ដែលត្រូវបានអនុម័តនៅក្រោមមាត្រា ៧ (៣) នៃពិធីសារតាមជម្រើសនៃអនុសញ្ញាស្ដីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ ទាក់ទងនឹងការប្រាស្រ័យទាក់ទងលេខ ១៤៦/២០១៩ គណៈកម្មាធិការលុបបំបាត់ការរើសអើងប្រឆាំងនឹងស្ត្រីភេទ

cambodia-court.

27 សូមមើល https://www.ohchr.org/en/press-releases/2023/07/cambodia-un-human-rights-chief-regrets-elections-held-restrictive.

28 សូមមើល https://cambodia.un.org/en/258915-press-freedom-and-journalists%E2%80%99-safety-are-lifeline-peace-development-and-sustainability.

បានរកឃើញថា ប្រទេសកម្ពុជាបានរំលោភបំពានលើសិទ្ធិក្នុងការទទួលភាពមិនរើសអើង និងសមភាព តាមផ្លូវច្បាប់របស់អ្នកការពារសិទ្ធិមនុស្ស ជាស្ត្រីជនបទម្នាក់ ដែលឈានមុខគេនៅក្នុងកិច្ចខិតខំ ប្រឹងប្រែងនៅក្នុងសហគមន៍របស់នាងដើម្បីបញ្ឈប់ការទិញដីធ្លីរបស់ក្រុមហ៊ុនអភិវឌ្ឍន៍ឯកជន។ ជាពិសេស គណៈកម្មាធិការបានរកឃើញថា ប្រទេសកម្ពុជាមិនបានការពារនាងពីការរើសអើង ការគំរាមកំហែង និងអំពើហិង្សាពីសំណាក់ក្រុមហ៊ុននោះទេ បានរៀបចំនីតិវិធីរឿងក្តីព្រហ្មទណ្ឌ ដែលបង្កើតឱ្យមានការសងសឹកចំពោះភាពជាសកម្មជនរបស់នាង និងមិនបានឆ្លើយតបនឹងញត្តិរបស់នាងទាក់ទងនឹងជម្លោះដីធ្លីនោះទេ។[29]

## VI. ការរួមបញ្ចូលយន្តការសិទ្ធិមនុស្សអន្តរជាតិ

### ក. កំណែទម្រង់ស្ថាប័ន និងច្បាប់

47. នៅខែធ្នូ ឆ្នាំ២០២៣ តាមសំណើរបស់ក្រសួងមហាផ្ទៃ ក្រុមការងារប្រចាំប្រទេសរបស់អង្គការសហប្រជាជាតិបានជាក់ជូនរដ្ឋាភិបាលនូវការវិភាគរបស់ខ្លួនលើសេចក្តីព្រាងវិសោធនកម្មច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ក្នុងគោលបំណងគាំទ្រដល់រដ្ឋាភិបាល ដើម្បីធានាបាននូវភាពអនុលោមតាមកាតព្វកិច្ចសិទ្ធិមនុស្សអន្តរជាតិរបស់ខ្លួន និងអនុសាសន៍ពីយន្តការសិទ្ធិមនុស្សអន្តរជាតិ។

48. នៅក្នុងការអង្កេតសន្និដ្ឋានរបស់ខ្លួន ក្នុងខែមីនា ឆ្នាំ២០២៤ គណៈកម្មាធិការស្តីពីការបាត់ខ្លួនដោយបង្ខំ បានសម្តែងការព្រួយបារម្ភចំពោះការលំបាកដែលត្រូវបានចោទប្រកាន់ នៅក្នុងនីតិវិធីចុះបញ្ជី ដែលកំណត់ដោយច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល និងបានផ្តល់អនុសាសន៍ថា ប្រទេសកម្ពុជាគួរតែពន្លឿនការត្រួតពិនិត្យច្បាប់នោះតាមរយៈការពិគ្រោះយោបល់ប្រកបដោយតម្លាភាពជាមួយអង្គការសង្គមស៊ីវិល និងភាគីពាក់ព័ន្ធដទៃទៀត។[30]

49. នៅថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០២៣ គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា បានដាក់ជូនទីស្តីការគណៈរដ្ឋមន្ត្រី នូវសេចក្តីព្រាងច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈកម្មាធិការជាតិសិទ្ធិមនុស្ស ដែលប្រសិនបើត្រូវបានអនុម័ត នឹងបង្កើតស្ថាប័នជាតិសិទ្ធិមនុស្សមួយ។ OHCHR កាលពីមុន ធ្លាប់ផ្តល់ដំបូន្មានផ្នែកបច្ចេកទេស និងការគាំទ្រដល់ការបង្កើតសេចក្តីព្រាងច្បាប់នោះ ក្នុងគោលបំណងធានាឱ្យមានភាពអនុលោមតាមគោលការណ៍នានា ដែលទាក់ទងនឹងស្ថានភាពរបស់ស្ថាប័នជាតិ ក្នុងការលើកកម្ពស់ និងការពារសិទ្ធិមនុស្ស (គោលការណ៍ទីក្រុងប៉ារីស)។ នៅក្នុងការអង្កេតសន្និដ្ឋានរបស់ខ្លួន គណៈកម្មាធិការស្តីពីការបាត់ខ្លួនដោយបង្ខំ បានអំពាវនាវឱ្យប្រទេសកម្ពុជាពន្លឿនដំណើរការបង្កើតស្ថាប័នជាតិសិទ្ធិមនុស្ស ដោយអនុលោមទាំងស្រុងតាមគោលការណ៍ទីក្រុងប៉ារីស។[31]

50. OHCHR បានបន្តផ្តល់ជំនួយបច្ចេកទេសដល់គណៈកម្មាធិការជាតិប្រឆាំងទារុណកម្ម នូវការកសាងសមត្ថភាព និងការចុះត្រួតពិនិត្យកន្លែងឃុំឃាំង ក្នុងចំណោមជំនួយដទៃទៀត ក្នុងគោលបំណង

[29] *X. v. Cambodia* (CEDAW/C/85/D/146/2019).

[30] CED/C/KHM/CO/1 កថាខណ្ឌទី ៦១ និង ៦២.

[31] Ibid. កថាខណ្ឌទី ១៥ និង ១៦.

ពង្រឹងតួនាទីរបស់ខ្លួន ក្នុងនាមជាយន្តការជាតិទប់ស្កាត់ការធ្វើទារុណកម្មនៅកម្ពុជា។ នៅខែមិថុនា និង ខែកញ្ញា ឆ្នាំ២០២៣ OHCHR បានរៀបចំវគ្គបណ្តុះបណ្តាលចំនួនបួន នៅក្នុងខេត្តចំនួនបួន ដល់មន្ត្រីអនុវត្តច្បាប់ មន្ត្រីពន្ធនាគារ មន្ត្រីតុលាការ និងមន្ត្រីរដ្ឋាភិបាលខេត្តចំនួន ៧៨៧ នាក់ (ស្ត្រី ១១០ នាក់ និងបុរស ៦៧៧ នាក់) ស្តីពីស្តង់ដារជាតិ និងអន្តរជាតិ ស្តីពីការទប់ស្កាត់ទារុណកម្ម ព្រមទាំង ស្តីពីតួនាទី និងភារកិច្ចរបស់គណៈកម្មាធិការជាតិប្រឆាំងទារុណកម្ម ពាក់ព័ន្ធនឹងការទប់ស្កាត់នេះផងដែរ។ នៅខែតុលា ឆ្នាំ២០២៣ OHCHR បានគាំទ្រដល់គណៈកម្មាធិការ ក្នុងការរៀបចំមហាសន្និបាតរបស់ខ្លួន ដែលបានគិតគូរអំពីការងារ និងវឌ្ឍនភាពរបស់ខ្លួនក្នុងការទប់ស្កាត់ និងដោះស្រាយទារុណកម្ម និងការធ្វើបាប ក្នុងអំឡុងពេលប្រាំឆ្នាំដំបូងនៃការដំណើរការគណៈកម្មាធិការនេះ។

51. នៅថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០២៣ រដ្ឋាភិបាលបានប្រកាសឱ្យប្រើព្រះរាជក្រឹត្យស្តីពីការបង្កើត ការរៀបចំ និងការប្រព្រឹត្តទៅនៃអាជ្ញាធរជាតិដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ។ នៅខែមករា ឆ្នាំ២០២៤ OHCHR បានដាក់ជូនរដ្ឋាភិបាល នូវកំណត់សម្គាល់នៃការវិភាគមួយ ដើម្បីពង្រឹងភាពអនុលោមតាមប្រព័ន្ធដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ រួមជាមួយកាតព្វកិច្ចសិទ្ធិមនុស្សអន្តរជាតិរបស់ប្រទេសកម្ពុជា។ នៅក្នុងកំណត់សម្គាល់នោះ OHCHR បានសង្កេតឃើញថា ក្នុងចំណោមបញ្ហាដទៃទៀត ព្រះរាជក្រឹត្យនោះមិនបានបញ្ជាក់អំពីយុត្តាធិការជាសក្តានុពលរបស់អាជ្ញាធរជាតិនោះទេ ដែលវានឹងអាស្រ័យលើច្បាប់ដទៃទៀត ដូចជា ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ជាដើម ដែលអនុញ្ញាតឱ្យមានសន្ទានកម្ម និងការផ្សះផ្សា នៅក្នុងសំណុំរឿង "អនីតិជន" នៃអំពើហិង្សាផ្លូវកាយ និងផ្លូវភេទ ព្រមទាំង គ្រប់សំណុំរឿងទាំងអស់នៃអំពើហិង្សាផ្លូវអារម្មណ៍ និងសេដ្ឋកិច្ច។ សមាជិកអាជ្ញាធរជាតិត្រូវបានតែងតាំងក្នុងខែវិច្ឆិកា ឆ្នាំ២០២៣ និងបានចាប់ផ្តើមទទួលសំណុំរឿង ចាប់ពីថ្ងៃទី០១ ខែមីនា ឆ្នាំ២០២៤។

## ខ. យន្តការសិទ្ធិមនុស្សអន្តរជាតិ

52. OHCHR បានបន្តផ្តល់យោបល់លើការអនុវត្តអនុសាសន៍ ដែលចេញដោយយន្តការសិទ្ធិមនុស្សអន្តរជាតិ ជាពិសេសសេចក្តីសន្និដ្ឋាននៃការសង្កេតការណ៍របស់ស្ថាប័នសន្ធិសញ្ញា។ OHCHR ក៏បានបន្តផ្សព្វផ្សាយសេចក្តីសន្និដ្ឋាននៃការសង្កេតការណ៍ទាំងនោះ និងបកប្រែឯកសារពាក់ព័ន្ធពីយន្តការសិទ្ធិមនុស្សអន្តរជាតិទៅជាភាសាខ្មែរផងដែរ។

53. នៅខែមិថុនា ឆ្នាំ២០២៣ OHCHR និងគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា បានសហការគ្នារៀបចំកិច្ចពិគ្រោះយោបល់ថ្នាក់ជាតិមួយសម្រាប់អ្នកចូលរួមចំនួន ៦៣ នាក់ (ស្ត្រី ៣៦ នាក់ និងបុរស ២៧ នាក់) មកពីរដ្ឋាភិបាល សង្គមស៊ីវិល និងអង្គភាពអង្គការសហប្រជាជាតិ ដើម្បីផ្សព្វផ្សាយ និងតាមដានទិដ្ឋភាពនៃសេចក្តីសន្និដ្ឋានអំពីការសង្កេតការណ៍របស់គណៈកម្មាធិការសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ ពាក់ព័ន្ធនឹងយេនឌ័រ[32] បន្ថែមលើសិក្ខាសាលាស្តីពីការសន្និដ្ឋានរបស់គណៈកម្មាធិការសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ កាលពីខែតុលា ឆ្នាំ២០២៣ ដូចបានរៀបរាប់ខាងលើ។

54. នៅខែកញ្ញា ឆ្នាំ២០២៣ OHCHR បានអញ្ជើញគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា ឱ្យចូលរួម

[32] CCPR/C/KHM/CO/3.

ក្នុងកិច្ចសន្ទនាមួយនៅទីក្រុងបាងកក ដែលរៀបចំដោយ OHCHR ស្ដីពីយន្តការជាតិសម្រាប់ការអនុវត្ត ការរាយការណ៍ និងការតាមដាននៅអាស៊ីអាគ្នេយ៍ ដើម្បីចែករំលែកបទពិសោធន៍របស់ខ្លួន និងរៀនសូត្រពីយន្តការជាតិដទៃទៀតនៅក្នុងតំបន់។ នៅខែតុលា ឆ្នាំ២០២៣ OHCHR ក៏បានបកប្រែ និងចែករំលែកជាមួយគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា នូវឯកសារណែនាំរបស់ OHCHR ដែលមានចំណងជើងថា *យន្តការជាតិសម្រាប់ការរាយការណ៍ និងការតាមដាន៖ មគ្គុទ្ទេសក៍ណែនាំអំពីការអនុវត្តការចូលរួមរបស់រដ្ឋនៅក្នុងយន្តការសិទ្ធិមនុស្សអន្តរជាតិប្រកបដោយប្រសិទ្ធភាព* ជាភាសាអង់គ្លេស និងភាសាខ្មែរ។

55. នៅខែកុម្ភៈ ឆ្នាំ២០២៤ OHCHR បានរៀបចំបណ្ដុំវគ្គបណ្ដុះបណ្ដាលកសាងសមត្ថភាព សំដៅពង្រឹងការចូលរួមរបស់ស្ថាប័នរដ្ឋាភិបាល ដូចជា គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា និងគណៈកម្មាធិការជាតិប្រឆាំងទារុណកម្ម នៅក្នុងយន្តការសិទ្ធិមនុស្សអន្តរជាតិ។ OHCHR បានផ្ដល់ព័ត៌មានដល់អ្នកចូលរួមអំពីគុណតម្លៃនៃមូលដ្ឋានទិន្នន័យតាមដានអនុសាសន៍ជាតិ ដែលខ្លួនបានបង្កើតឡើង និងតួនាទីរបស់យន្តការជាតិក្នុងការអនុវត្ត ការរាយការណ៍ និងការតាមដាន។

56. នៅខែកក្កដា និង ខែកញ្ញា ឆ្នាំ២០២៣ OHCHR បានគាំទ្រដល់សង្គមស៊ីវិល ក្នុងការរៀបចំសិក្ខាសាលាពិគ្រោះយោបល់ស្ដីពីការរៀបចំការដាក់ជូនឯកសាររបស់ភាគីពាក់ព័ន្ធសម្រាប់វគ្គនៃការត្រួតពិនិត្យតាមកាលកំណត់ជាសកលលើកទីបួនរបស់ប្រទេសកម្ពុជា ដែលបានធ្វើឡើងនៅថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០២៤ ដោយផ្ដោតជាពិសេសលើអង្គការជនពិការ និងអង្គការជនជាតិដើមភាគតិច។ OHCHR ក៏បានសម្របសម្រួលឱ្យមានការចូលរួមពីតំណាងអង្គការមិនមែនរដ្ឋាភិបាលចំនួន ១១ នាក់ នៅក្នុងកិច្ចប្រជុំមុនពេលត្រួតពិនិត្យតាមកាលកំណត់ជាសកល នៅទីក្រុងហ្សឺណែវ ក្នុងខែកុម្ភៈ ឆ្នាំ២០២៤ ផងដែរ។ OHCHR ក៏បានដឹកនាំការរៀបចំរបាយការណ៍ក្រុមការងារប្រចាំប្រទេសរបស់អង្គការសហប្រជាជាតិ ដើម្បីគាំទ្រដល់ការត្រួតពិនិត្យតាមកាលកំណត់ជាសកល ដែលត្រូវបានដាក់ជូននៅថ្ងៃទី១១ ខែតុលា ឆ្នាំ២០២៣ ផងដែរ។

57. OHCHR បានគាំទ្រគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជាក្នុងការរៀបចំរបាយការណ៍ជាតិសម្រាប់ការត្រួតពិនិត្យតាមកាលកំណត់ជាសាកល ការតស៊ូមតិដើម្បីអភិក្រមដែលមានការចូលរួម និងរៀបចំសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិនៅថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០២៣ ដែលមានអ្នកចូលរួមចំនួន ១១៥ នាក់ (ស្ត្រី ៣០ នាក់ និងបុរស ៨៥ នាក់) មកពីរដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល និងអង្គការអន្តរជាតិ។ បន្ទាប់មក នៅថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២៤ OHCHR បានផ្ដល់ព័ត៌មានសង្ខេបដល់ប្រតិភូរដ្ឋាភិបាល ដែលបានចូលរួមសម័យប្រជុំក្រុមការងារត្រួតពិនិត្យតាមកាលកំណត់ជាសកល នៅខែឧសភា ឆ្នាំ២០២៤ អំពីដំណើរការត្រួតពិនិត្យតាមកាលកំណត់ជាសកល។ ក្នុងអំឡុងពេលធ្វើរបាយការណ៍នេះ OHCHR បានរៀបចំវគ្គបណ្ដុះបណ្ដាលចំនួនប្រាំ ដើម្បីផ្ដល់ចំណេះដឹងដល់តំណាងចំនួន ២៧ នាក់ (ស្ត្រី ៨ នាក់ និងបុរស ១៩ នាក់) មកពីអង្គការមិនមែនរដ្ឋាភិបាល ចំនួន ២២ អង្គការ ស្ដីពីច្បាប់សិទ្ធិមនុស្សអន្តរជាតិ និងការចូលរួមជាមួយយន្តការសិទ្ធិមនុស្សអន្តរជាតិ ក្នុងគោលបំណងបង្កើតក្រុមបណ្ដុះបណ្ដាលដែលមានសមត្ថភាពគ្រប់គ្រាន់លើប្រធានបទទាំងនេះ។

58. នៅខែវិច្ឆិកា ឆ្នាំ២០២៣ OHCHR បានចូលរួមចំណែកដល់ដំណើរទស្សនកិច្ចដើម្បីការតស៊ូមតិនៅកម្ពុជា របស់គណៈកម្មាធិការសិទ្ធិកុមារ ក្រោមការសម្របសម្រួលរបស់មូលនិធិកុមាររបស់អង្គការសហប្រជាជាតិ (យូនីសេហ្វ) ដើម្បីពិភាក្សាអំពីវិធីពន្លឿនការអនុវត្តការអង្កេតសន្និដ្ឋានរបស់គណៈ-កម្មាធិការ រួមទាំងការបង្កើត អាជ្ញាធរឯករាជ្យសម្រាប់កិច្ចការពារសិទ្ធិកុមារ (child rights ombudsperson) នៅក្រោមស្ថាប័នសិទ្ធិមនុស្សថ្នាក់ជាតិទូលំទូលាយ ដែល OHCHR បានធ្វើការតស៊ូមតិអស់រយៈពេលជាច្រើនឆ្នាំមកហើយ។

## គ. ការបញ្ជ្រាបសិទ្ធិមនុស្សតាមរយៈក្រុមការងារប្រចាំប្រទេសរបស់អង្គការសហប្រជាជាតិ

59. OHCHR បានបន្តចូលរួមជាមួយក្រុមការងារប្រចាំប្រទេសរបស់អង្គការសហប្រជាជាតិ ក្នុងការបញ្ជ្រាបសិទ្ធិមនុស្ស រួមទាំង សមភាពយេនឌ័រ នៅក្នុងក្របខណ្ឌជាតិ ការវិភាគប្រចាំប្រទេស និងក្របខណ្ឌកិច្ចសហប្រតិបត្តិការក្នុងការអភិវឌ្ឍន៍ប្រកបដោយចីរភាពរបស់អង្គការសហប្រជាជាតិសម្រាប់ប្រទេសកម្ពុជា ឆ្នាំ២០២៤-២០២៨ ដែលរដ្ឋាភិបាលបានអនុម័តបន្ទាប់ពីមានដំណើរការពិគ្រោះយោបល់ជាមួយក្រុមការងារប្រចាំប្រទេសរបស់អង្គការសហប្រជាជាតិ និងភាគីពាក់ព័ន្ធដទៃទៀតអស់រយៈពេលមួយឆ្នាំ និងត្រូវបានបោះពុម្ពផ្សាយក្នុងខែវិច្ឆិកា ឆ្នាំ២០២៣។[33] OHCHR ប្តេជ្ញាចិត្តផ្តល់លទ្ធផល នៅក្រោមវិស័យអាទិភាពនៃការអភិវឌ្ឍចំនួន ៤ ស្តីពីបរិវត្តកម្មសង្គមនៅក្នុងក្របខណ្ឌកិច្ចសហប្រតិបត្តិការ ដែលផ្តោតលើគណនេយ្យភាព ការចូលរួមរបស់ពលរដ្ឋ និងសមភាពយេនឌ័រ។

60. OHCHR សហការជាមួយក្រុមការងារប្រចាំប្រទេសរបស់អង្គការសហប្រជាជាតិ បានប្រារព្ធពិធីគម្រប់ខួប ៧៥ឆ្នាំ នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស ដោយរៀបចំពិព័រណ៍យុវជនអង្គការសហប្រជាជាតិ នៅខែតុលា ឆ្នាំ២០២៣ ដែលបានរួមបញ្ចូលយុវជនចំនួន ៧២៦ នាក់ ក្នុងការលើកកម្ពស់សង្គមដែលមានសន្តិភាព យុត្តិធម៌ និងប្រកបដោយបរិយាប័ន្ន។ OHCHR ក៏បានរៀបចំព្រឹត្តិការណ៍កម្រិតខ្ពស់មួយ នៅខែធ្នូ ឆ្នាំ២០២៣ នៅរាជធានីភ្នំពេញផងដែរ ដែលមានការចូលរួមពីតំណាងរដ្ឋាភិបាល សហគមន៍អន្តរជាតិ សង្គមស៊ីវិល និងប្រជាជនដែលស្ថិតក្នុងស្ថានភាពងាយរងគ្រោះ ចំនួន ៣០០ នាក់ និងបានបង្កើតយុទ្ធនាការប្រព័ន្ធផ្សព្វផ្សាយសង្គម ដើម្បីលើកកម្ពស់ការយល់ដឹងអំពីសិទ្ធិមនុស្សនៅទូទាំងប្រទេស ជាផ្នែកមួយនៃការប្រារព្ធខួបនោះដែរ។[34]

# VII. គណនេយ្យភាព និងការគ្រប់គ្រងយុត្តិធម៌

## ក. ការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

61. ប្រទេសកម្ពុជានៅតែជាប្រទេសប្រភពដើម និងជាប្រទេសគោលដៅ ដែលរងផលប៉ះពាល់ដោយអំពើជួញដូរមនុស្ស។ កាលពីឆ្នាំមុន រដ្ឋាភិបាលបានប្រកាសវិធានការជាច្រើនដើម្បីដោះស្រាយអំពើជួញដូរមនុស្ស ប៉ុន្តែនៅតែមានបញ្ហាប្រឈម។ ក្នុងអំឡុងពេលធ្វើរបាយការណ៍នេះ OHCHR បន្តទទួលបានរបាយការណ៍ស្តីពីការជួញដូរមនុស្សនៅក្នុងប្រទេសកម្ពុជា រួមទាំងរបាយការណ៍ស្តីពីប្រតិបត្តិការ

[33] សូមមើល https://cambodia.un.org/en/252482-united-nations-sustainable-development-cooperation-framework-2024-2028.

[34] សូមមើល https://twitter.com/OHCHR_Cambodia/status/1733047908025655456.

ខុសច្បាប់នៃមជ្ឈមណ្ឌលបោកប្រាស់តាមអនឡាញក្នុងខេត្តព្រះសីហនុ រាជធានីភ្នំពេញ ខេត្តកណ្ដាល ខេត្តកោះកុង ក្រុងប៉ោយប៉ែត ខេត្តពោធិ៍សាត់ ខេត្តស្វាយរៀង និងខេត្តកំពត។ របាយការណ៍ទាំងនោះ បានចង្អុលបង្ហាញថា ជនដែលត្រូវបានចោទប្រកាន់ថា ត្រូវគេជួញដូរដើម្បីបង្ខំឲ្យប្រព្រឹត្តិបទឧក្រិដ្ឋនៅក្នុងមជ្ឈមណ្ឌលទាំងនេះ មានកុមារផងដែរ។

62. នៅថ្ងៃទី១៦ ខែមករា ឆ្នាំ២០២៤ អ្នកសម្របសម្រួលអង្គការសហប្រជាជាតិ អមដោយតំណាង OHCHR អង្គការអន្តរជាតិទេសន្តរប្រវេសន៍ និងកម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ បានជួបជាមួយអនុប្រធានអចិន្ត្រៃយ៍នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស លោកជំទាវ ជូ ប៊ុនអេង ដើម្បីពិភាក្សាអំពីបញ្ហាប្រឈមនាពេលបច្ចុប្បន្ន ទាក់ទងនឹងការឆ្លើយតបទៅនឹងអំពើជួញដូរមនុស្សនៅកម្ពុជា។ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សបានសង្កត់ធ្ងន់លើតួនាទីដ៏សំខាន់របស់ផែនការយុទ្ធសាស្ត្រជាតិ ឆ្នាំ២០២៤-២០២៨ ដែលរំពឹងថានឹងបោះពុម្ពផ្សាយនៅឆ្នាំ២០២៤ នឹងមាននៅក្នុងការពង្រឹងកិច្ចខិតខំប្រឹងប្រែងក្នុងការដោះស្រាយអំពើជួញដូរមនុស្សនៅកម្ពុជា ដោយលោកជំទាវបានទទួលស្គាល់ថា បញ្ហានេះទទួលបានការយកចិត្តទុកដាក់កាន់តែខ្លាំង ក្នុងរយៈពេលបីឆ្នាំកន្លងមក។ ផែនការយុទ្ធសាស្ត្រជាតិព្យាយាមពង្រឹងការឆ្លើយតបរបស់ប្រទេសកម្ពុជាចំពោះអំពើជួញដូរមនុស្ស តាមរយៈវិស័យសំខាន់ៗចំនួនបួន រួមមាន ការពង្រឹងកិច្ចសហប្រតិបត្តិការក្នុងការអភិវឌ្ឍ និងការអនុវត្តច្បាប់ និងគោលនយោបាយដែលពាក់ព័ន្ធ ការលើកកម្ពស់ការបង្ការទប់ស្កាត់ ការពង្រឹងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ និងការបង្កើនកិច្ចការពារជនរងគ្រោះ។ រដ្ឋាភិបាលក៏បានរួមបញ្ចូលការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ជាកិច្ចការមួយនៅក្នុងយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ ផងដែរ។

63. នៅក្នុងការអង្កេតសន្និដ្ឋានរបស់ខ្លួន គណៈកម្មាធិការស្ដីពីការបាត់ខ្លួនដោយបង្ខំបានសម្ដែងការព្រួយបារម្ភអំពីកង្វះខាតធនធាន និងការសម្របសម្រួលសម្រាប់ការអនុវត្តផែនការសកម្មភាពជាតិស្ដីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ឆ្នាំ២០១៩-២០២៣ ក្នុងចំណោមបញ្ហាដទៃទៀត។ គណៈកម្មាធិការនេះបានផ្ដល់អនុសាសន៍ថា រដ្ឋភាគីគួរតែអនុវត្តផែនការសកម្មភាពជាតិប្រកបដោយប្រសិទ្ធភាព តាមរយៈការធានាថាមានធនធាន និងការសម្របសម្រួលសមស្រប ការស៊ើបអង្កេតយ៉ាងហ្មត់ចត់លើការចោទប្រកាន់ពីអំពើជួញដូរមនុស្ស និងធានាបាននូវការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងបញ្ជូនពួកគេទៅទទួលសេវាសមស្របយ៉ាងឆាប់រហ័ស។[35]

64. យោងតាមគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស អាជ្ញាធរអនុវត្តច្បាប់កម្ពុជាបានចាត់វិធានការលើករណីអំពើជួញដូរមនុស្សចំនួន ២៤ ករណី (ដែលមានជនល្មើស ៣៤ នាក់ និងជនរងគ្រោះ ២០៤ នាក់ ក្នុងនោះមានស្ត្រី ៧៨ នាក់) និង ១៤០ ករណី ពាក់ព័ន្ធនឹងការជួញដូរផ្លូវភេទ (ដែលមានជនល្មើស ១៦០ នាក់ និងជនរងគ្រោះ ២៧២ នាក់ ក្នុងនោះមានស្ត្រី ២៦៨ នាក់) ទាក់ទងនឹងពាក្យបណ្ដឹងដែលទទួលបាននៅក្នុងឆ្នាំ២០២៣។ ក្រសួងការបរទេស និងកិច្ចសហប្រតិបត្តិការអន្តរជាតិបានរាយការណ៍ថា នៅឆ្នាំ២០២៣ រដ្ឋាភិបាលបានផ្ដល់ការគាំទ្រដល់ការធ្វើមាតុភូមិនិវត្តន៍

[35] CED/C/KHM/CO/1 paras. 45 and 46.

របស់ប្រជាជនកម្ពុជាចំនួន ៧.៩៥៣ នាក់មកពីក្រៅប្រទេស ដែលត្រូវការជំនួយ ដោយគណៈកម្មាធិការជាតិបានរាយការណ៍ថា ក្នុងចំណោមការធ្វើមាតុភូមិនិវត្តន៍ទាំងនោះ មានតែ ១៦២ នាក់ប៉ុណ្ណោះ ដែលពាក់ព័ន្ធនឹងករណីអំពើជួញដូរមនុស្ស។

65. គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សក៏បានរាយការណ៍ផងដែរថា នៅឆ្នាំ២០២៣ មានមនុស្សចំនួន ៤.៣១៤ នាក់ ត្រូវបានចាប់ខ្លួនពីបទល្មើសអន្តោប្រវេសន៍ ប្រសិនបើប្រៀបធៀបនឹងមនុស្សចំនួន ១០៥ នាក់ ដែលត្រូវបានចាប់ខ្លួនពីបទឧក្រិដ្ឋផ្សេងៗ ដូចជា ការបោកប្រាស់តាមអនឡាញ ការជំរិតទារប្រាក់ អំពើជួញដូរមនុស្ស ឬការបៀតបៀនផ្លូវភេទ ជាដើម និងថា អាជ្ញាធរបានបណ្តេញជនបរទេសចំនួន ២.១៥៩ នាក់ ដែលបានប្រព្រឹត្តបទឧក្រិដ្ឋនៅប្រទេសកម្ពុជាចេញពីប្រទេស ទោះបីជាមានភាពមិនច្បាស់លាស់ថាតើ ករណីទាំងនោះជាប់ពាក់ព័ន្ធនឹងអំពើជួញដូរមនុស្សដែរឬទេ។

66. រដ្ឋាភិបាលបានរាយការណ៍ថា ខ្លួនបានចាត់វិធានការដោះស្រាយស្ថានភាពនានា ដែលធ្វើឱ្យប្រជាជនងាយរងគ្រោះដោយអំពើជួញដូរមនុស្ស និងផ្តល់ការគាំទ្រដល់ជនរងគ្រោះដោយបទឧក្រិដ្ឋដែលអាចស្ថិតក្នុងស្ថានភាពដែលធ្វើឱ្យពួកគេងាយរងគ្រោះដោយអំពើជួញដូរមនុស្សផងដែរ។ យោងតាមគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស អាជ្ញាធរកម្ពុជាបានយកកុមារចំនួន ២៩៤ នាក់ ចេញពីស្ថានភាពនៃការកេងប្រវ័ញ្ច និងបានផ្តល់ការគាំទ្រដល់ពួកគេ ដើម្បីឱ្យពួកគេអាចបន្តការសិក្សា និងទទួលបានជំនាញវិជ្ជាជីវៈ។ អាជ្ញាធរកម្ពុជាបានរាយការណ៍ថា ខ្លួនបានរៀបចំពាក្យបណ្តឹងទាមទារសំណងជូនជនរងគ្រោះចំនួន ១៣ នាក់ នៃបទល្មើសព្រហ្មទណ្ឌដែលពាក់ព័ន្ធ និងបានបញ្ជូនជនរងគ្រោះចំនួន ៤៣៦ នាក់ (ស្ត្រី ៣៥៦ នាក់ និងបុរស ៧១ នាក់) និងជនដែលស្ថិតក្នុងស្ថានភាពធ្វើឱ្យពួកគេងាយរងគ្រោះដោយអំពើជួញដូរមនុស្ស ទៅកាន់អង្គការដៃគូ ដើម្បីស្តារនីតិសម្បទា។ ទីភ្នាក់ងាររដ្ឋាភិបាលក៏បានរាយការណ៍ថា បានត្រួតពិនិត្យការធ្វើសមាហរណកម្មជនរងគ្រោះកម្ពុជាចំនួន ២៨៣ នាក់ (ស្ត្រី ២៤៦ នាក់ និងបុរស ៣៧ នាក់) ដែលរងគ្រោះពីការរៀបការដោយបង្ខំ ការកេងប្រវ័ញ្ចកម្លាំងពលកម្ម និងការរំលោភបំពានផ្លូវភេទ និងអ្នកដទៃទៀតដែលស្ថិតក្នុងស្ថានភាពងាយរងគ្រោះ ឲ្យត្រឡប់ទៅកាន់សហគមន៍វិញ។ នៅខែសីហា ឆ្នាំ២០២៣ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សបានបើកវគ្គបណ្តុះបណ្តាលថ្មីមួយស្តីពីការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្សដើម្បីផ្តល់សេវាសមស្រប សំដៅពង្រឹងកិច្ចខិតខំប្រឹងប្រែងសង្គ្រោះ និងជួយជីវិតជនរងគ្រោះ នៅខណៈពេលជាមួយគ្នា ត្រួតពិនិត្យឡើងវិញលើបទដ្ឋាន និងយុទ្ធសាស្ត្រនានានៅទូទាំងប្រទេសផងដែរ។

## ខ. លក្ខខណ្ឌក្នុងការឃុំខ្លួន

67. យោងតាមទិន្នន័យរបស់អគ្គនាយកដ្ឋានពន្ធនាគារ ក្នុងខែឧសភា ឆ្នាំ២០២៤ ប្រជាជននៅក្នុងពន្ធនាគារមានចំនួន ៤៦.៥៧៥ នាក់ (ស្ត្រី ២.៧៨៨ នាក់ និងបុរស ៤៣.១៤៨ នាក់) មានការកើនឡើងជាង ១៧ ភាគរយ ប្រសិនបើប្រៀបធៀបនឹងខែមីនា ឆ្នាំ២០២៣។ ទោះបីជាមានកិច្ចខិតខំប្រឹងប្រែងរបស់ក្រសួងយុត្តិធម៌ក្នុងការដោះស្រាយការកើនឡើងនៃចំនួនប្រជាជននៅ ២៩ ពន្ធនាគារសម្រាប់អ្នកទោសកម្រិតធ្ងន់នៅប្រទេសកម្ពុជាក៏ដោយ ក៏ពន្ធនាគារនៅតែបន្តមានចំនួនអ្នកទោសលើស

កម្រិតដែរ។ ក្នុងចំណោមគំនិតផ្តួចផ្តើមដទៃទៀត រដ្ឋាភិបាលបាន និងកំពុងសិក្សាលើការអនុវត្តវិធានការជំនួសការឃុំឃាំង ជាមធ្យោបាយមួយដើម្បីកាត់បន្ថយភាពចង្អៀតខ្លាំងពេកនៅក្នុងពន្ធនាគារ។

68. ក្នុងគោលបំណងកែលម្អការគ្រប់គ្រងយុត្តិធម៌ និងរួមចំណែកដល់ការដោះស្រាយភាពចង្អៀតខ្លាំងពេកនៅក្នុងពន្ធនាគារ OHCHR បានបន្តផ្តល់ការគាំទ្រដល់ក្រសួងយុត្តិធម៌ លើមូលដ្ឋានទិន្នន័យសំណុំរឿងព្រហ្មទណ្ឌ ដែលជាកម្មវិធីគេហទំព័រមួយសម្រាប់រក្សាទុក និងតាមដានទិន្នន័យ ពាក់ព័ន្ធនឹងសំណុំរឿងព្រហ្មទណ្ឌ។ នៅឆ្នាំ២០២៣ OHCHR បានផ្តល់ការគាំទ្រដល់ក្រសួង លើការតភ្ជាប់មូលដ្ឋានទិន្នន័យទៅកាន់ម៉ាស៊ីនមេកណ្តាល នៅសាលាដំបូងចំនួនប្រាំបីកន្លែងបន្ថែមទៀត ជាលទ្ធផលសាលាដំបូងនៅទូទាំង ២៥ ខេត្ត និងតុលាការប្រចាំតំបន់ចំនួនបួន ត្រូវបានតភ្ជាប់ទៅកាន់ម៉ាស៊ីនមេជាលើកដំបូង។ នៅខែសីហា និង ខែកញ្ញា ឆ្នាំ២០២៣ OHCHR និងក្រសួងយុត្តិធម៌បានធ្វើការវាយតម្លៃរួមគ្នាលើការប្រើប្រាស់ និងការដំណើរការមូលដ្ឋានទិន្នន័យនៅសាលាដំបូង ចំនួន ១៤ កន្លែង អមដោយវគ្គបណ្តុះបណ្តាលបន្ថែមសម្រាប់បុគ្គលិកតុលាការចំនួន ៧១ នាក់ (ស្ត្រី ៣៣ នាក់ និងបុរស ៣៨ នាក់)។ ផ្អែកលើការវាយតម្លៃនេះ OHCHR បានផ្តល់ការគាំទ្រដល់ការបង្កើតមុខងារថ្មីចំនួនពីរ ដែលអនុញ្ញាតឱ្យចៅក្រម ព្រះរាជអាជ្ញា និងក្រឡាបញ្ជី ចូលប្រើប្រាស់ប្រព័ន្ធមូលដ្ឋានទិន្នន័យ ដើម្បីបើកមើលទិន្នន័យ និងរយៈពេលនៃការឃុំខ្លួនបណ្តោះអាសន្ន ដែលបានកន្លងផុតទៅសម្រាប់សំណុំរឿងដែលស្ថិតក្រោមទំនួលខុសត្រូវរបស់ពួកគេ។

69. នៅខែកញ្ញា ឆ្នាំ២០២៣ គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា បានតែងតាំងមន្ត្រីប្រាំរូប ដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការជាមួយ OHCHR ក្នុងការផ្លាស់ប្តូរព័ត៌មាន ទាក់ទងនឹងការរំលោភបំពានលើសិទ្ធិមនុស្ស ដែលត្រូវបានចោទប្រកាន់ នៅកន្លែងឃុំឃាំង។ នៅខែឧសភា ឆ្នាំ២០២៤ អគ្គនាយកដ្ឋានពន្ធនាគារបានយល់ព្រមផ្តល់ជូន OHCHR នូវសិទ្ធិចេញចូលកន្លែងឃុំឃាំងរយៈពេលមួយឆ្នាំ ដែលមានរយៈពេលវែងជាងការព្រមព្រៀងលើសិទ្ធិចេញចូលកាលពីមុន ដែលមានរយៈពេលតែប្រាំមួយខែប៉ុណ្ណោះ។

70. ក្នុងអំឡុងពេលធ្វើរបាយការណ៍នេះ OHCHR បានធ្វើការចុះសួរសុខទុក្ខចំនួន ១៨ លើក នៅពន្ធនាគារប្រាំបួនកន្លែង។ ក្នុងអំឡុងពេលធ្វើទស្សនកិច្ចទាំងនោះ OHCHR បានចងក្រងឯកសារអំពីកង្វល់ទាក់ទងនឹងសិទ្ធិទទួលបានការថែទាំសុខភាព លទ្ធភាពទទួលបានទឹកស្អាត និងការមិនរើសអើង។ OHCHR ក៏បានទទួលការចោទប្រកាន់អំពីការស៊ីសំណូក ក្នុងចំណោមអ្នកជាប់ឃុំ និងមន្ត្រីពន្ធនាគារផងដែរ។

71. នៅក្នុងពន្ធនាគារភាគច្រើនដែលពួកគេបានទៅសួរសុខទុក្ខ អ្នកទោសដែលត្រូវបានសម្ភាសដោយ OHCHR បានរាយការណ៍ថា ពួកគេមិនទទួលការត្រួតពិនិត្យសុខភាពជាទៀងទាត់នោះទេ ដោយបានប្រឈមមុខនឹងការទទួលបានឱសថតិចតួច និងមានការពិបាកក្នុងការចូលទៅប៉ុស្តិ៍សុខភាព ដែលជាដំបូង ពួកគេត្រូវបានតម្រូវឲ្យមានការអនុម័តពីប្រធានមន្ទីរឃុំឃាំងរបស់ពួកគេ ដែលបន្ទាប់មក ប្រធានមន្ទីរឃុំឃាំងនោះនឹងបញ្ជូនសំណើរបស់ពួកគេទៅកាន់អាជ្ញាធរពន្ធនាគារ។ មន្ត្រីពេទ្យនៅពន្ធនាគារម្នាក់បានប្រាប់ OHCHR ថា ប៉ុស្តិ៍សុខភាពមិនមានបុគ្គលិកគ្រប់គ្រាន់សម្រាប់ផ្តល់

ការគាំទ្រដល់អ្នកទោសជាង ១.០០០ នាក់នោះទេ ដោយបានបន្ថែមថា ភាពចង្អៀតខ្លាំងពេកធ្វើឱ្យមានការលំបាកក្នុងការគ្រប់គ្រងជំងឺឆ្លង។ នៅពន្ធនាគារនៃខេត្តមួយ មន្ត្រីពន្ធនាគារបានស្នើសុំជំនួយពី OHCHR ដើម្បីបង្កើតបន្ទប់សុវត្ថិភាព ដែលនាំយកអ្នកទោសមកកាន់ទីនោះ និងធ្វើការព្យាបាល នៅពេលដែលប៉ុស្តិ៍សុខភាពមិនអាចផ្តល់ការថែទាំសុខភាពបានគ្រប់គ្រាន់។

72. OHCHR ក៏បានទទួលរបាយការណ៍អំពីលទ្ធភាពទទួលបានទឹកស្អាតសម្រាប់ពិសារយ៉ាងមានកម្រិតផងដែរ។ ស្ត្រីនៅមណ្ឌលកែប្រែទី២ ដែលត្រូវបានសម្ភាសដោយ OHCHR បានត្អូញត្អែរថា អាជ្ញាធរពន្ធនាគារមិនបានផ្លាស់ប្តូរម៉ាស៊ីនចម្រោះទឹកដែលខូចជាច្រើនគ្រឿង និងថា ពួកគេប្រឈមមុខនឹងការប្រព្រឹត្តចំពោះពួកគេខុសៗគ្នា ក្នុងការចូលផ្ទះបាយដើម្បីដាំទឹក ដែលហាក់បីដូចជាផ្អែកលើទំនាក់ទំនងផ្ទាល់ខ្លួន ឬប្រតិបត្តិការផ្នែកសេដ្ឋកិច្ច។ អាជ្ញាធរពន្ធនាគារនៅមណ្ឌលកែប្រែទី២ បានបញ្ជាក់ប្រាប់ OHCHR ថា មិនមែនតែងតែមានទឹកម៉ាស៊ីននោះទេ ហើយពួកគេបានប្រើទឹកស្រះសម្រាប់បោកសម្លៀកបំពាក់ ហើយនៅពេលខ្លះ ក៏សម្រាប់ចម្អិនម្ហូបអាហារផងដែរ។ OHCHR ក៏បានទទួលរបាយការណ៍នៅក្នុងពន្ធនាគារមួយចំនួនផងដែរថា ប្រធានពន្ធនាគារដែលទទួលខុសត្រូវបែងចែកលទ្ធភាពប្រើប្រាស់បង្គន់ និងកន្លែងបោកសម្លៀកបំពាក់ បានទទួលប្រាក់កម្រៃពីអ្នកទោសសម្រាប់អាទិភាពក្នុងការប្រើប្រាស់។ OHCHR បានទទួលព័ត៌មានបន្ថែមទៀតថា មានតម្រូវការផលិតផលអនាម័យស្ត្រីបន្ថែមទៀត នៅក្នុងមណ្ឌលកែប្រែទី២ ដូចជា សំឡីអនាម័យ ជាដើម។

## គ. ជំនួយផ្នែកច្បាប់

73. OHCHR បានបន្តផ្តល់ការគាំទ្រដល់គំនិតផ្តួចផ្តើមនៃជំនួយផ្នែកច្បាប់ រួមទាំងការផ្តល់ហិរញ្ញប្បទានឥតសំណងដល់អង្គការសង្គមស៊ីវិលចំនួនពីរ ដើម្បីផ្តល់ជំនួយផ្នែកច្បាប់ដល់ជនដែលស្ថិតក្នុងស្ថានភាពងាយរងគ្រោះ។ OHCHR បានជួបប្រជុំជាទៀងទាត់ ជាមួយអង្គការមិនមែនរដ្ឋាភិបាល ដែលផ្តល់សេវាផ្លូវច្បាប់ដល់អ្នកការពារសិទ្ធិមនុស្ស និងជនរងគ្រោះនៃការរំលោភបំពានសិទ្ធិមនុស្ស ដែលបានសម្គាល់ឃើញបញ្ហាប្រឈមជាច្រើនក្នុងការផ្តល់ជំនួយផ្នែកច្បាប់ ដូចជា ការលំបាកផ្នែកមូលនិធិ និងការថយចុះនៃចំនួនមេធាវីដែលដោះស្រាយសំណុំរឿងសិទ្ធិមនុស្ស។

# VIII. សេចក្តីសន្និដ្ឋាន និងអនុសាសន៍

**74. អគ្គលេខាធិការស្វាគមន៍ការចូលរួមជាវិជ្ជមានរបស់រដ្ឋាភិបាលជាមួយ OHCHR និងបានគូសបញ្ជាក់អំពីតួនាទីដ៏សំខាន់របស់ OHCHR ក្នុងការផ្តល់ជំនួយដល់រដ្ឋាភិបាល និងប្រជាជនកម្ពុជា ក្នុងការលើកកម្ពស់សិទ្ធិមនុស្សសម្រាប់មនុស្សគ្រប់រូប ដោយមិនមានការបែងចែក។ អគ្គលេខាធិការនៅតែមានកង្វល់អំពីការរឹតត្បិតនៃលំហពលរដ្ឋ និងសិទ្ធិមនុស្ស រួមទាំងសិទ្ធិចូលរួមក្នុងកិច្ចការសាធារណៈ នៅក្នុងបរិបទនៃការបោះឆ្នោតថ្នាក់ជាតិ សិទ្ធិក្នុងការជួបជុំដោយសន្តិវិធី និងសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ និងការបង្កើតសមាគម។**

75. **អគ្គលេខាធិការ អំពាវនាវឲ្យរដ្ឋាភិបាល៖**

(ក) **បន្តការចូលរួមជាវិជ្ជមានជាមួយ OHCHR ដើម្បីលើកកម្ពស់សិទ្ធិមនុស្សសម្រាប់**

មនុស្សគ្រប់រូប រួមទាំងបន្តអនុស្សរណៈនៃការយោគយល់គ្នាជាមួយ OHCHR សម្រាប់រយៈពេលប្រាំឆ្នាំទៀត ដើម្បីលើកកម្ពស់និរន្តរភាពនៃសកម្មភាពកិច្ចសហប្រតិបត្តិការផ្នែកបច្ចេកទេស

(ខ) បែងចែកធនធានអតិបរមាដែលមាន នៅក្នុងវិស័យសង្គមកិច្ច ដើម្បីសម្រេចបាននូវវឌ្ឍនភាពនៃសិទ្ធិសេដ្ឋកិច្ច និងសង្គមកិច្ចសម្រាប់មនុស្សគ្រប់រូប រួមទាំងតាមរយៈការបង្កើនចំណាយសាធារណៈជាច្រើននៅក្នុងផ្នែកសន្តិសុខសង្គម ការថែទាំសុខភាព និងការអប់រំ ក្នុងគោលបំណងកាត់បន្ថយវិសមភាព

(គ) ធានាថា ថវិកាជាតិត្រូវបានរៀបចំយ៉ាងប្រុងប្រយ័ត្ន និងអនុវត្តប្រកបដោយតម្លាភាព និងមានការចូលរួម ជាពិសេសធានាបាននូវទិន្នន័យដែលបានការបែងចែក ស្ដីពីការចាត់ចែង និងចំណាយជាក់ស្ដែងនៃថវិការដ្ឋាភិបាល នៅតាមក្រសួង កម្មវិធី និងការចាត់ថ្នាក់ផ្នែកសេដ្ឋកិច្ច និងមុខងារ

(ឃ) ធានាថាគម្រោងកិច្ចគាំពារសង្គម ក្របខណ្ឌ គោលនយោបាយ និងច្បាប់នានា ត្រូវបានបង្កើតឡើង ស្របតាមស្តង់ដារសិទ្ធិមនុស្ស និងស្តង់ដារការងារអន្តរជាតិ រួមទាំង ក្របខណ្ឌគោលនយោបាយ និងច្បាប់ដែលទាក់ទងនឹងគោលការណ៍នៃភាពអាចផ្តត់ផ្គង់បាន ភាពគ្រប់គ្រាន់ភាពជាសកល តម្លាភាព និងការមិនរើសអើងនៅក្នុងដំណើរការរដ្ឋបាល និងឆ្លើយតបនឹងយេនឌ័រ ដើម្បីផ្តល់កិច្ចគាំពារសង្គមជាសកលដល់ប្រជាជនគ្រប់រូប ជាពិសេសអ្នកធ្វើការនៅក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ ដែលភាគច្រើនជាស្ត្រី

(ង) ធ្វើវិសោធនកម្មច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ ដើម្បីកំណត់ ហាមឃាត់ និងកាត់ទោស គ្រប់ទម្រង់នៃអំពើហិង្សាយេនឌ័រ អនុលោមតាមកាតព្វកិច្ចសិទ្ធិមនុស្សអន្តរជាតិរបស់ប្រទេសកម្ពុជា

(ច) បង្កើតច្បាប់អាពាហ៍ពិពាហ៍ភេទដូចគ្នា និងទទួលស្គាល់អត្តសញ្ញាណយេនឌ័រ ស្របតាមអនុសាសន៍ ដែលប្រទេសកម្ពុជាធ្លាប់បានទទួលកាលពីមុន ក្នុងអំឡុងវដ្តនៃការត្រួតពិនិត្យតាមកាលកំណត់ជាសកលលើកទីបី

(ឆ) អនុម័ត និងអនុវត្តផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព ឆ្នាំ២០២៤-២០២៨ ដោយប្រើអភិក្រមផ្អែកលើសិទ្ធិមនុស្ស ដើម្បីបញ្ចប់សេចក្តីព្រាងច្បាប់ស្តីពីកិច្ចការពារសិទ្ធិជនពិការអនុលោមតាមស្តង់ដារសិទ្ធិមនុស្សអន្តរជាតិ និងដាក់ជូនរបាយការណ៍តាមកាលកំណត់លើកទីមួយជូនគណៈកម្មាធិការសិទ្ធិជនពិការ ដោយមិនមានភាពយឺតយ៉ាវ

(ជ) ពង្រឹងលំហពលរដ្ឋ និងប្រជាធិបតេយ្យ តាមរយៈការការពារសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយរបស់ប្រជាជនគ្រប់រូប ដោយគ្មានការបែងចែក រួមទាំងសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ ការជួបជុំដោយសន្តិវិធី និងការបង្កើតសមាគម កំណែទម្រង់ច្បាប់ និងគោលនយោបាយ ដើម្បីធានាបាននូវការចូលរួមប្រកបដោយប្រសិទ្ធភាព និងប្រកបដោយអត្ថន័យរបស់ប្រជាជនគ្រប់រូប ជាពិសេសស្ត្រី និងអង្គការនានា នៅក្នុងដំណើរការធ្វើសេចក្តីសម្រេច រួមទាំងការបោះឆ្នោតផងដែរ និងចាត់វិធាន

ការចាំបាច់ដើម្បីដោះលែងជនដែលត្រូវបានឃុំខ្លួនតាមអំពើចិត្ត ចំពោះការអនុវត្តសិទ្ធិមនុស្សរបស់ពួកគេ និងបញ្ឈប់ និងទប់ស្កាត់ការបំភិតបំភ័យអ្នកការពារសិទ្ធិមនុស្ស តួអង្គសង្គមស៊ីវិល និងតួអង្គនយោបាយ

(ឈ) អនុម័តច្បាប់ស្តីពីការបង្កើតគណៈកម្មការជាតិសិទ្ធិមនុស្ស និងច្បាប់ស្តីពីគណៈកម្មាធិការជាតិប្រឆាំងទារុណកម្ម អនុលោមតាមស្តង់ដារសិទ្ធិមនុស្សអន្តរជាតិ រួមទាំងការធានាឯករាជ្យភាពនៃមុខងារ និងប្រតិបត្តិការរបស់ពួកគេ

(ញ) បន្តចូលរួមជាមួយយន្តការសិទ្ធិមនុស្សអន្តរជាតិ និងអនុវត្តអនុសាសន៍របស់ពួកគេ រួមទាំងការចេញពីស្ថាប័នសន្ធិសញ្ញាអង្គការសហប្រជាជាតិ និងការត្រួតពិនិត្យតាមកាលកំណត់ជាសកល និងធានាថា ភាគីពាក់ព័ន្ធទាំងអស់ ជាពិសេសសង្គមស៊ីវិល ត្រូវបានពិគ្រោះយោបល់ និងអាចចូលរួមក្នុងការរៀបចំរបាយការណ៍ជាតិ ស្របតាមយន្តការសិទ្ធិមនុស្សអន្តរជាតិ បានយ៉ាងមានប្រសិទ្ធភាព និងប្រកបដោយអត្ថន័យ

(ដ) ចាត់វាល់វិធានការចាំបាច់ទាំងអស់ រួមទាំងតាមរយៈការអនុវត្តផែនការយុទ្ធសាស្ត្រជាតិ ឆ្នាំ២០២៤-២០២៨ ប្រកបដោយប្រសិទ្ធភាព ដើម្បីដោះស្រាយមូលហេតុឫសគល់នៃអំពើជួញដូរមនុស្ស ធ្វើការស៊ើបអង្កេត និងកាត់ទោសអ្នកទទួលខុសត្រូវប្រកបដោយប្រសិទ្ធភាព និងធានាបាននូវការកំណត់អត្តសញ្ញាណយ៉ាងទាន់ពេលវេលា ការបញ្ជូនបន្ត ការស្តារនីតិសម្បទា និងសមាហរណកម្មជនរងគ្រោះចូលទៅក្នុងសង្គម រួមទាំងការធានាថា មានធនធានសមស្រប និងការសម្របសម្រួលក្នុងចំណោមអាជ្ញាធរមានសមត្ថកិច្ច

(ឋ) កាត់បន្ថយភាពចង្អៀតខ្លាំងពេកនៅក្នុងពន្ធនាគារ និងកែលម្អលក្ខខណ្ឌក្នុងការឃុំឃាំង តាមរយៈការពង្រឹងវិធានការជំនួសការឃុំឃាំង ការអនុវត្តគោលនយោបាយជាតិស្តីពីជំនួយផ្នែកច្បាប់ ដែលត្រូវបានអនុវត្តដោយមានធនធានគ្រប់គ្រាន់ និងការកែលម្អរដ្ឋបាលយុត្តិធម៌ រួមទាំងតាមរយៈការអភិវឌ្ឍប្រកបដោយវឌ្ឍនភាព និងការប្រើប្រាស់ប្រព័ន្ធមូលដ្ឋានទិន្នន័យសំណុំរឿងព្រហ្មទណ្ឌ ដែលត្រូវបានបង្កើតឡើងដោយមានការគាំទ្រពី OHCHR។